រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សៀវភៅណែនាំ
# ស្តីពី
# គោលការណ៍សំខាន់ៗជាមូលដ្ឋាន
# សម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ខែមិថុនា ឆ្នាំ២០០៩
លេខាធិការដ្ឋាន គ.ជ.អ.ប
បោះពុម្ពលើកទី១ ចំនួន ៨,០០០ច្បាប់

## មាតិកា

អារម្ភកថា ១

ផ្នែកទី១

ទស្សនទានសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល
រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

១. ទស្សនទានស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៣
១.១. និយមន័យ ៣
១.២. ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ ៥
១.៣. មូលហេតុនៃការអនុវត្តកំណែទម្រង់ ៧
១.៤. គោលដៅនៃកំណែទម្រង់ ៨
១.៥. ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ៩
១.៥.១ ក្របខ័ណ្ឌគោលនយោបាយ ៩
១.៥.២. ក្របខ័ណ្ឌច្បាប់ ១២
២. បទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១៤
២.១. គោលបំណង ១៤
២.២. ការរៀបចំដែនដី ១៤

២.៣. រដ្ឋបាលឯកភាព ១៦

២.៤. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ១៧

**៣. រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ២០**

៣.១. រចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ២០

៣.២. តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ២១

៣.២.១. ក្រុមប្រឹក្សា ២១

៣.២.២. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ៣៤

៣.២.៣. គណៈអភិបាល ៣៨

៣.២.៤. នាយករដ្ឋបាល ៤៣

៣.២.៥. បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា ៤៥

៣.២.៦. គណនេយ្យភាព ៤៦

**៤. ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ ៤៩**

៤.១. ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី ជាមួយក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ៤៩

៤.២. ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់ ៥០

៤.៣. ទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ៥០

៤.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ៥១

៤.៥. ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៥៣

| | | |
|---|---|---|
| ៤.៥.១. | គោលការណ៍ទូទៅ | ៥៣ |
| ៤.៥.២. | តួនាទីរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ | ៥៦ |
| ៤.៥.៣. | តួនាទីរបស់ គ.ជ.អ.ប | ៥៧ |


## ផ្នែកទី២

## របៀបរបបគ្រប់គ្រងទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ


| | | |
|---|---|---|
| ១ | ផ្នែកកិច្ចការរដ្ឋបាល | ៦១ |
| ២. | ផ្នែកគ្រប់គ្រងបុគ្គលិក | ៦៧ |
| ៣. | ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ | ៧០ |
| ៤. | ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ | ៧២ |
| ៥. | ផ្នែកកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ | ៧៥ |


## ផ្នែកទី៣

## បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា


| | | |
|---|---|---|
| ១. | អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង | ៨៤ |
| ២. | ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា | ៨៦ |
| ២.១. | ពាក្យគន្លឹះ | ៨៧ |
| ២.២. | អំពីកិច្ចប្រជុំក្រុមប្រឹក្សា | ៩២ |
| ២.៣. | អំពីរបៀបរបបប្រជុំក្រុមប្រឹក្សា | ៩៧ |
| ២.៤. | អំពីជីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា | ១០២ |
| ២.៥. | សិទ្ធិអំណាចរបស់ប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា | ១០៥ |
| ២.៦. | អំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា | ១០៨ |
| ២.៧. | តួនាទី ភារកិច្ច និងសិទ្ធិរបស់គណៈអភិបាល និងនាយករដ្ឋបាល | ១០៩ |
| ២.៨. | ការខកខានមិនបានចូលរួមប្រជុំ | ១១១ |
| ២.៩. | ការកែប្រែបទបញ្ជាផ្ទៃក្នុង | ១១៣ |


## ផ្នែកទី៤

## ការរៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សា


| | | |
|---|---|---|
| ១. | ទស្សនទាននៃការរៀបចំផែនការសកម្មភាពការងារ | ១១៤ |
| ២. | ផែនការសកម្មភាពការងាររយៈពេលបីខែរបស់ក្រុមប្រឹក្សា | ១១៦ |
| ២.១. | គោលបំណង | ១១៧ |
| ២.២. | អ្នកពាក់ព័ន្ធ និងតួនាទី | ១១៨ |
| ២.៣. | ដំណើរការរៀបចំផែនការការងារសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា | ១១៩ |
| ២.៤. | ការអនុវត្តផែនការសកម្មភាពការងារ | ១២៨ |
| ២.៥. | ការតាមដានត្រួតពិនិត្យ និងរបាយការណ៍ | ១២៩ |

# អារម្ភកថា

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) រៀបចំសៀវភៅនេះឡើងក្នុងគោលបំណងដើម្បីជួយដល់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលទើបចូលកាន់តំណែងអាចអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យស្របតាមស្មារតីនៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

សៀវភៅនេះចែកចេញជា បួនផ្នែកធំៗ ដែលរួមមាន :

- **ផ្នែកទី១** : ទស្សនទានសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **ផ្នែកទី២** : របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- **ផ្នែកទី៣** : ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- **ផ្នែកទី៤** : ការរៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សា

ទោះបីជាឯកសារណែនាំនេះ មានខ្លឹមសារធំៗពុំលម្អិតក្តី ក៏លេខាធិការដ្ឋាន គ.ជ.អ.ប សង្ឃឹមថា ឯកសារនេះនឹងក្លាយជាមូលដ្ឋានសម្រាប់





ត្រួសត្រាយផ្លូវឱ្យក្រុមប្រឹក្សាអាណត្តិទី១ ដែលទើបជាប់ឆ្នោតថ្មីនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចចាប់ផ្តើមបំពេញការងាររបស់ខ្លួនបាន។

លេខាធិការដ្ឋាន គ.ជ.អ.ប កំពុងសម្របសម្រួលរៀបចំលិខិតបទដ្ឋាននានាជាច្រើន ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ បន្ទាប់ពីមានលិខិតបទដ្ឋានទាំងនោះ លេខាធិការដ្ឋាននឹងពិនិត្យ និងកែសម្រួលសៀវភៅណែនាំនេះជាបន្តបន្ទាប់ឱ្យស្របតាមការវិវឌ្ឍនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងទទួលស្វាគមន៍ជានិច្ចនូវមតិទិតៀនស្ថាបនា ដើម្បីកែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

# ផ្នែកទី១
# ទស្សនទានសំខាន់ៗនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ





## ១. ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ១.១. និយមន័យ

#### ១.១.១. វិមជ្ឈការ

វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាល **ប្រគល់នូវភាពជាម្ចាស់** លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។

**ឧទាហរណ៍ :**

រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួន ៤០លានរៀល សម្រាប់ជាថវិការបស់រដ្ឋបាលស្រុកមួយក្នុងគោលដៅនៃការអភិវឌ្ឍ។ ក្រុមប្រឹក្សាស្រុកនោះមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្រុក ដោយផ្អែកតាមកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ស្រុក ដែលបានអនុម័តដោយក្រុមប្រឹក្សា ដូចជាសម្រាប់ជីកអណ្តូងទឹកស្អាត ជួសជុលផ្លូវលំ និងផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍តាមតម្រូវការរបស់ប្រជាពលរដ្ឋជាដើម។

ក្នុងន័យនេះ ថវិកា៤០លានរៀល រដ្ឋាភិបាលបានផ្តល់នូវភាពជាម្ចាស់ក្នុងការគ្រប់គ្រងដល់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាមានភាពជាម្ចាស់ក្នុងការជ្រើសរើសគម្រោងមួយចំនួនដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយប្រើប្រាស់ថវិកានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ថវិកាទាំងនេះ ក្រុមប្រឹក្សាត្រូវតែអនុវត្តតាមនីតិវិធីដែលបានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានស្តីពីថវិកាស្រុក។

### ១.១.២. វិសហមជ្ឈការ

វិសហមជ្ឈការមានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន **ធ្វើប្រតិភូកម្ម** មុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។

**ឧទាហរណ៍ ១ :**

ក្រសួងកសិកម្ម ធ្វើប្រតិភូកម្មមុខងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅឱ្យមន្ទីរកសិកម្មខេត្ត ព្រមទាំងផ្តល់ធនធាន និងបច្ចេកទេសឱ្យមន្ទីរកសិកម្មខេត្ត ដើម្បីផ្សព្វផ្សាយដល់ប្រជាកសិករនៅក្នុងខេត្តរបស់ខ្លួន។ មន្ទីរកសិកម្មខេត្តធ្វើការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម តាមការណែនាំរបស់ក្រសួងកសិកម្ម និងក្នុងនាមជាតំណាងឱ្យក្រសួងកសិកម្ម។





**ឧទាហរណ៍ ២ :**

ក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្មមុខងារធ្វើសេចក្តីចម្លងអត្រានុកូលដ្ឋានទៅឱ្យក្រុមប្រឹក្សាស្រុក ហើយអភិបាលស្រុកត្រូវបានប្រគល់ឱ្យអនុវត្តការងារនេះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ក្នុងការធ្វើប្រតិភូកម្មមុខងារនេះ ក្រសួងមហាផ្ទៃនឹងផ្តល់នូវធនធាន និងការបណ្តុះបណ្តាលសមត្ថភាព ដល់អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។ អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុក អនុវត្តការចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋក្នុងស្រុករបស់ខ្លួន តាមការណែនាំពីក្រសួងមហាផ្ទៃ និងក្នុងនាមក្រសួងមហាផ្ទៃ។

## ១.២. ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ

តាមរយៈនិយមន័យទាំងពីរខាងលើ ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់ដូចខាងក្រោម :

| វិមជ្ឈការ | វិសហមជ្ឈការ |
|---|---|
| - គោលបំណងដើម្បី ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅថ្នាក់រដ្ឋបាលក្រោមជាតិ | - គោលបំណងដើម្បីបង្កិតការទទួលខុសត្រូវរបស់រដ្ឋឱ្យទៅជិតប្រជា-ពលរដ្ឋ និងធ្វើឱ្យការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋកាន់តែរហ័ស និងមានប្រសិទ្ធភាព |

| | |
|---|---|
| - អង្គភាពអនុវត្ត គឺជានីតិបុគ្គលដាច់ដោយឡែក | - អង្គភាពអនុវត្តមិនមែនជានីតិបុគ្គលដោយឡែកពីថ្នាក់ជាតិទេ |
| - មានតំណាងដែលកើតចេញពីបោះឆ្នោតតាមបែបប្រជាធិបតេយ្យ | - មន្ត្រីអនុវត្តកើតចេញពីការតែងតាំង |
| - ធ្វើជាតំណាងឱ្យអ្នកបោះឆ្នោត | - ធ្វើជាតំណាងឱ្យរដ្ឋាភិបាលថ្នាក់ជាតិ |
| - ទទួលខុសត្រូវផ្ទាល់ចំពោះអ្នកបោះឆ្នោត និងប្រយោលចំពោះរាជរដ្ឋាភិបាល | - ទទួលខុសត្រូវផ្ទាល់ត្រូវចំពោះរាជរដ្ឋាភិបាលថ្នាក់ជាតិ |
| - តម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ | - មិនតម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ |
| - មានថវិកា ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិដោយឡែក | - ថវិកា ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិជារបស់ជាតិ |
| - ទទួលអំណាចតាមរយៈការផ្ទេរពីថ្នាក់ជាតិ | - ទទួលអំណាចតាមរយៈការធ្វើប្រតិភូកម្មពីថ្នាក់ជាតិ |
| - មានភាពជាម្ចាស់ក្នុងការអនុវត្ត | - អនុវត្តក្នុងនាមស្ថាប័នដែលធ្វើប្រតិភូកម្មឱ្យ |

ដូច្នេះវិមជ្ឈការ និងវិសហមជ្ឈការ គឺជារបៀបគ្រប់គ្រងពីរផ្សេងគ្នា ប៉ុន្តែរបៀបគ្រប់គ្រងទាំងពីរនេះ ជាការបំពេញឱ្យគ្នាទៅវិញទៅមកក្នុងគោលបំណងរួម គឺសំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវានានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។





## ១.៣. មូលហេតុនៃការអនុវត្តកំណែទម្រង់

រាជរដ្ឋាភិបាលចាត់ទុកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កិតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយរំពឹងថានឹងទទួលបាននូវផលប្រយោជន៏ធំៗចំនួនបីដូចខាងក្រោម :

- **ទី១ :** ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ដែលនេះគឺជាការពង្រឹង និងពង្រីកនូវការចូលរួមជាសាធារណៈ នៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើលទ្ធផលនៃការចូលរួមនេះ តម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះ តាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានភាពល្អប្រសើរ និងការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត។

- **ទី២ :** ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាព ព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះត្រូវបានផ្ទេរ ឬបង្កិតឱ្យទៅជិតប្រជាពលរដ្ឋ។

- **ទី៣ :** ការបង្កើននូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានរបស់វិស័យឯកជននានាឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋានក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

## ១.៤. គោលដៅនៃកំណែទម្រង់

ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បីបង្កើត និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលដៅជាយុទ្ធសាស្ត្របីគឺ :

- ពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និង
- ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន សំដៅលើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍មូលដ្ឋាន។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្រខាងលើ កំណែទម្រង់ចាំបាច់ត្រូវរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ





ក្នុងគោលបំណងដើម្បី :

- ធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទូលំទូលាយ សំដៅពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន
- ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន
- បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រ ក្រុមជនងាយរងគ្រោះ ជនជាតិដើម ជនជាតិភាគតិច ស្ត្រី និងកុមារ យុវជន យុវនារី...។

## ១.៥. ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ១.៥.១. ក្របខ័ណ្ឌគោលនយោបាយ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ត្រូវបានផ្តួចផ្តើម និងយកចិត្តទុកដាក់តាំងពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ ហើយនឹងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ នៅក្នុងអាណត្តិទី២នៃរាជរដ្ឋាភិបាលកម្ពុជា។ តាមរយៈសមិទ្ធផលដ៏ជោគជ័យនៃការយកចិត្តទុកដាក់ និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងអាណត្តិទី២នៃរាជរដ្ឋាភិ

បាល រាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រឹងពង្រីកការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅថែមទៀត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានរៀបចំអនុម័តក្របខ័ណ្ឌគោលនយោបាយមួយចំនួន ដើម្បីត្រួសត្រាយផ្លូវសម្រាប់កំណែទម្រង់នេះរួមមាន :

- យុទ្ធសាស្ត្រចតុកោណ និង
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## ក). យុទ្ធសាស្ត្រចតុកោណ

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងដំណាក់កាលទី២ ដែលត្រូវបានទទួលស្គាល់ជាបុរេលក្ខខណ្ឌសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។ ដើម្បីសម្រេចនូវអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់កំណែទម្រង់លើវិស័យចំនួនបួនរួមមាន :

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ និង
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលចាត់ទុកថា **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** មានសារៈសំខាន់ចំពោះការកែលម្អគុណភាពនៃសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។





## ខ). ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានកំណត់អំពី :

- ចក្ខុវិស័យរបស់រដ្ឋាភិបាលអំពីកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

## ១.៥.២. ក្របខំណ្ឌច្បាប់

ដោយផ្អែកតាមក្របខ័ណ្ឌគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់ទាំងពីរនេះត្រូវបានកំណត់ថាជា "ច្បាប់រៀបចំអង្គការ" ។

### ក). ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាលចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួននៅថ្នាក់ឃុំ សង្កាត់ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០១ ។

ច្បាប់នេះកំណត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានមុខងារពីរ គឺ :

- មុខងារផ្ទាល់ដែលជាមុខងារបម្រើកិច្ចការមូលដ្ឋាន គឺការបម្រើផលប្រយោជន៍ជូនប្រជាពលក្នុងឃុំ សង្កាត់របស់ខ្លួន
- មុខងារជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

### ខ). ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ដើម្បីអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានរៀបចំចងក្រងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង





ស្រុក ខណ្ឌ ដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភាឆ្នាំ២០០៨។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាល បន្តពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

ដើម្បីអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋាននានាជាច្រើនទៀត ហើយទាមទារឱ្យមានការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានទាំងនោះជាបន្តបន្ទាប់ផងដែរ ។

# ២. បទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ២.១. គោលបំណង

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

## ២.២. ការរៀបចំទឹកដី

កន្លងមកនេះទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចែកជាខេត្ត និង ក្រុង ដែល :

- ខេត្ត ចែកជាស្រុក ហើយស្រុកចែកជាឃុំ
- ក្រុង ចែកជាខណ្ឌ ហើយខណ្ឌចែកជាសង្កាត់

ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញលើមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី ដែលបានដាក់ឱ្យប្រើប្រាស់កាលពី ខែកុម្ភៈ ឆ្នាំ២០០៨ បានបើកផ្លូវសម្រាប់កែសម្រួលការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែសមស្របនឹងស្ថានភាពជាក់ស្តែង។ មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា ទឹកដីព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ហើយ





មាត្រា ១៤៦ថ្មីចែងផងដែរថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់ គ្រងតាមលក្ខខណ្ឌ ដែលមានក្នុងច្បាប់រៀបចំអង្គការ។

ផ្អែកតាមស្មារតីនៃវិសោធនកម្មរដ្ឋធម្មនុញ្ញខាងលើមាត្រា៤ និងមាត្រា៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម :

- ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា
- រាជធានីភ្នំពេញចែកជាខណ្ឌ ហើយខណ្ឌចែកជាសង្កាត់
- ខេត្តចែកជា
  - ក្រុង ហើយ ក្រុងចែកជា សង្កាត់
  - ស្រុក ចែកជា ឃុំ និងជា សង្កាត់។

**គំនូសបំព្រួញអំពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា**



ផ្អែកតាមការកំណត់នេះ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា រួមមាន ៖

- រាជធានីភ្នំពេញ
- ខេត្ត ចំនួន ២៣
- ក្រុង ចំនួន ២៦
- ស្រុក ចំនួន ១៥៩
- ខណ្ឌ ចំនួន ៨
- ឃុំចំនួន ១៤១៧
- សង្កាត់ចំនួន ២០៤

## ២.៣. រដ្ឋបាលឯកភាព

ច្បាប់រៀបចំអង្គការបានតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព។

ដើម្បីធានានូវគោលការណ៍នៃរដ្ឋបាលឯកភាព ក្រុមប្រឹក្សាត្រូវមានលទ្ធភាព ៖

- ម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន និង
- សមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងការផ្តល់





សេវា និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលទាំងនេះ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន។

**ឧទាហរណ៍** ៖ ដើម្បីធានានូវគោលការណ៍នៃរដ្ឋបាលឯកភាពក្នុងខេត្តមួយមានន័យថា ក្រុមប្រឹក្សាខេត្តនោះត្រូវមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ដែលរួមមានធនធានហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិដែលខ្លួនមាន និងត្រូវធ្វើការសម្របសម្រួលសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗរបស់មន្ទីរជំនាញជុំវិញខេត្ត និងអង្គភាពនានារបស់រដ្ឋាភិបាលដែលមាននៅក្នុងដែនដីខេត្តនោះ ដើម្បីឆ្លើយតបតម្រូវការប្រជាពលរដ្ឋក្នុងខេត្តរបស់ខ្លួន។

## ២.៤. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

តាមគោលការណ៍ច្បាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន ៖

- **ភាពជាតំណាងសាធារណៈ** ៖ ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- **ស្វ័យភាពរបស់មូលដ្ឋាន :** ក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែងគ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬធ្វើប្រតិភូកម្មឱ្យដោយច្បាប់នេះ ប្រកបដោយប្រសិទ្ធភាព
- **ការពិគ្រោះយោបល់ និងការចូលរួម :** ក្នុងដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេច ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងលើកទឹកចិត្តឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ
- **ការឆ្លើយតប និងគណនេយ្យភាព :** ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត ហើយក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរដ្ឋាភិបាល
- **ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន** សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បី :
  - បង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព
  - លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង





  - លើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- **ការលើកស្ទួយសមធម៌ :** ជាការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច
- **តម្លាភាព និងសុច្ចរិតភាព :** ជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុច្ចរិតភាព និងច្បាប់ ក្នុងលក្ខណៈបើកចំហ តម្លាភាព ភាពចូលរួម ភាពឆ្លើយតប
- **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច :** ជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច។

# ៣. រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ៣.១. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

យោងមាត្រា១៤, ១១៤, ១១៥, ១៣៨, ១៨៣, ១៨៩ រចនាសម្ព័ន្ធទូទៅនៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ មានដូចខាងក្រោម :




រចនាសម្ព័ន្ធជាក់ស្តែងនៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ នឹងកំណត់ដោយលិខិតបទដ្ឋានដោយឡែក ។





## ៣.២. តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. ក្រុមប្រឹក្សា

#### ក). សិទ្ធិអំណាចក្រុមប្រឹក្សា

យោងមាត្រា៣០ ក្រុមប្រឹក្សាមានសិទ្ធិអំណាចពីរគឺ :

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ

☞ **សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ** ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា។ ដីកា គឺជាវិធានខាងផ្លូវច្បាប់ ដែលបានអនុម័តដោយក្រុមប្រឹក្សា។ ដីការបស់ក្រុមប្រឹក្សាមានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សា។ ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សាត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬលើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់។

☞ **សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ** ក្រុមប្រឹក្សាត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថា សេចក្តីសម្រេចនោះ ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

## ខ). តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា

តួនាទី ភារកិច្ចជាចម្បងរបស់ក្រុមប្រឹក្សា គឺត្រូវធានាឱ្យមានការផ្តល់សេវា និងការអភិវឌ្ឍជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ដើម្បីចាត់ចែង តួនាទីភារកិច្ចនេះប្រកបដោយតម្លាភាព និងគណនេយ្យភាព ក្រុមប្រឹក្សាត្រូវរៀបចំយន្តការ និងកិច្ចការជាច្រើនដូចជា :

- **កសាងផែនការ :** ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ
- **គ្រប់គ្រងហិរញ្ញវត្ថុ :** ក្រុមប្រឹក្សារៀបចំ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- **តាមដានត្រួតពិនិត្យ និងវាយតម្លៃ :** ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជាទៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយរាប់បញ្ចូលទាំងផ្នែកនៃផែនការអភិវឌ្ឍន៍ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :





  - ក្រុមប្រឹក្សាប្រភេទរួមគ្នា
  - ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
  - ក្រសួង ស្ថាប័ន អង្គភាព នានារបស់រាជរដ្ឋាភិបាល និង
  - អ្នកពាក់ព័ន្ធនានា។
- **គ្រប់គ្រងបុគ្គលិក :** ក្រុមប្រឹក្សាត្រូវពិនិត្យ និងសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងផលប្រយោជន៍ផ្សេងទៀតរបស់បុគ្គលិក
- **រៀបចំរបាយការណ៍** ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ អំពី :
  - របាយការណ៍ប្រចាំឆ្នាំ ដែលពាក់ព័ន្ធនឹងការអនុវត្តដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ
  - របាយការណ៍អំពីសកម្មភាពនានាដែលបានអនុវត្ត
  - របាយការណ៍ហិរញ្ញវត្ថុ
  - របាយការណ៍អំពីការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា
  - របាយការណ៍អំពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ
  - វិធានការណ៍ចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា
  - ...។ល។

- **ផ្សព្វផ្សាយព័ត៌មាន :** ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលឱ្យសាធារណជនទទួលព័ត៌មានអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា។ ដូច្នេះក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្តារព័ត៌មានជាសាធារណៈ នៅមុខសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ដែលទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋពិនិត្យមើលព័ត៌មានលើក្តារព័ត៌មានទាំងនោះ ឬប្រជាពលរដ្ឋអាចមានទំនាក់ទំនងជាមួយសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីអានឯកសារទាំងនោះ។ ទន្ទឹមនេះ ក្រុមប្រឹក្សាអាចចាត់ឱ្យគណៈអភិបាលរិះរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតដូចជា ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ការបង្កើតឱ្យមានគេហទំព័រ ទស្សនាវដ្តី... ។ល។
- **រាយការណ៍អំពីសកម្មភាពរំលោភអំណាច :** ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ





- **ដោះស្រាយវិវាទ :** ក្រុមប្រឹក្សាត្រូវចាត់វិធានការសម្របសម្រួលដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ វិវាទនៅមូលដ្ឋាន គឺជាវិវាទមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នា ឬដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា។ ការដោះស្រាយវិវាទត្រូវផ្អែកតាមពាក្យបណ្តឹងរបស់ភាគីណាមួយ ឬភាគីទាំងសងខាង។ ក្នុងការដោះស្រាយវិវាទ ក្រុមប្រឹក្សាមិនត្រូវធ្វើសេចក្តីសម្រេចទៅលើបញ្ហា ដែលពាក់ពាក់ព័ន្ធនឹងករណីដូចខាងក្រោម :
    - ការលែងលះ
    - អំពើហិង្សាក្នុងគ្រួសារដែលមានចរិតលក្ខណៈជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម
    - បទល្មើសឧក្រិដ្ឋ ឬមជ្ឈិម ឬករណីស្ថិតក្នុងក្របខ័ណ្ឌសណ្តាប់ធ្នាប់សាធារណៈ
    - វិវាទដែលកំពុងដោះស្រាយដោយតុលាការ ឬមានសេចក្តីសម្រេចពីតុលាការ
    - វិវាទដែលច្បាប់ ឬដែលរដ្ឋាភិបាលបានកំណត់ឱ្យស្ថាប័ន ឬយន្តការជាក់លាក់ណាមួយដោះស្រាយ។

**បញ្ជាក់ :** តួនាទី និងភារកិច្ចលម្អិតរបស់ក្រុមប្រឹក្សា នឹងមានកំណត់ដោយលិខិតបទដ្ឋានដោយឡែកជាបន្តបន្ទាប់ទៀត ។

## គ). ការប្រជុំរបស់ក្រុមប្រឹក្សា

☞ **ប្រភេទនៃការប្រជុំ** ការប្រជុំរបស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញ ។

- **ការប្រជុំសាមញ្ញ :** ក្រុមប្រឹក្សា ត្រូវប្រជុំសាមញ្ញនៅក្នុងដែនដីរបស់ខ្លួន យ៉ាងហោចណាស់ចំនួនដប់ពីរ(១២) ដងជារៀងរាល់ឆ្នាំ។ អង្គប្រជុំសាមញ្ញលើកទី១របស់ក្រុមប្រឹក្សា ត្រូវប្រារព្ធឡើងមិនឱ្យហួសពីដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា។ កិច្ចប្រជុំសាមញ្ញនីមួយៗរបស់ក្រុមប្រឹក្សាត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬលើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនឡើយ ។ ក្រុមប្រឹក្សាត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន សម្រាប់រយៈពេលដប់ពីរ(១២)ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងសម្រាប់រយៈពេលជាបន្តទៀតក្នុងរយៈពេលដប់ពីរ(១២)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់។ ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈ និងបន្ទាន់នូវប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ។





- **ការប្រជុំវិសាមញ្ញ :** ក្រុមប្រឹក្សាអាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ ។

☞ **ប្រធានអង្គប្រជុំ** ប្រធានក្រុមប្រឹក្សា គឺជាប្រធានអង្គប្រជុំ នៅគ្រប់អង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សា ធ្វើជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតក្នុងលំដាប់លេខរៀងបន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលជាប់ឆ្នោតលំដាប់ទី២ក្នុងក្រុមប្រឹក្សា ដើម្បីធ្វើជាអធិបតីនៃអង្គប្រជុំ។ ករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលជាប់ឆ្នោតលំដាប់ទី២ក្នុងក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សា ដែលស្ថិតក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះឱ្យធ្វើជាអធិបតីនៃអង្គប្រជុំ។ ប្រធានអង្គប្រជុំរបស់ក្រុមប្រឹក្សាមានភារកិច្ច :

- ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនលំអៀង
- គោរព អនុវត្តច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា។

☞ **កូរ៉ុមនៃការប្រជុំ**

- រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សានឹងមានសុពលភាពទៅបានលុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សា មិនតិចជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល មានន័យថាប្រសិនបើក្រុមប្រឹក្សាមាន :

| ចំនួនសមាជិកក្រុមប្រឹក្សាសរុប | កូរ៉ុមសម្រាប់ប្រជុំ |
|---|---|
| - ២១ រូប | - ១១ រូប |
| - ១៩ រូប | - ១០ រូប |
| - ១៧ រូប | - ០៩ រូប |
| - ១៥ រូប | - ០៨ រូប |
| - ១៣ រូប | - ០៧ រូប |
| - ០៩ រូប | - ០៥ រូប |
| - ០៧ រូប | - ០៤ រូប |

- សមាជិកក្រុមប្រឹក្សាគ្រប់រូប ដែលមានវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សា មានសិទ្ធិបោះឆ្នោតមួយសម្លេង ដើម្បីអនុម័តរាល់ការសម្រេចរបស់ក្រុមប្រឹក្សា ។
- ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬសេចក្តីសម្រេចរបស់ខ្លួនដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។





☞ ការប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែក្រុមប្រឹក្សាក៏អាចប្រជុំជាសម្ងាត់ផងដែរ ។ កិច្ចដំណើការប្រជុំជាសម្ងាត់ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**បញ្ជាក់ :** ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវអនុម័តដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាបានអនុម័តសេចក្តីសម្រេចនោះ នឹងពុំមានសុពលភាពឡើយ ។

## ឃ). ការរំលោភអំណាច និងធ្វើមិនស្របច្បាប់

☞ **ការរំលោភអំណាច** ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬអ្នកដែលទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬក្នុងក្រុមប្រឹក្សាណាមួយបានប្រព្រឹត្តអំពើដោយចេតនា ហើយមិនអាចធ្វើយុត្តិកម្មបាន ដូចជា :

- ការប្រើប្រាស់តួនាទី អំណាចរបស់ខ្លួនដើម្បីកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈណាមួយ ។
- ការមិនប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនណាម្នាក់ដែលស្ថិតនៅក្រោមអំណាច ឬការត្រួតពិនិត្យរបស់ខ្លួន នៅ

ពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់ជនណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈ ។

☞ **សកម្មភាពរំលោភអំណាចរួមមានដូចខាងក្រោម :**

- ការរំលោភសិទ្ធិស្របច្បាប់ ឬសិទ្ធិមនុស្សរបស់ជនណាម្នាក់
- ការកាន់កាប់ ឬការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់
- ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ
- ការដកយកថវិកា ឬទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដោយមិនត្រឹមត្រូវ
- ការស្នើសុំ ឬការទទួលប្រាក់ ឬរង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬមិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬរង្វាន់នោះមិនបានកំណត់ក្នុងច្បាប់
- ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស
- ភាពមិនប្រក្រតីក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា
- ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៏ផ្ទាល់ខ្លួន ឬផលប្រយោជន៏គ្រួសាររបស់ខ្លួន





☞ ក្នុងករណីមានការរំលោភអំណាចកើតឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរ ជាបន្ទាន់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

☞ **ទង្វើមិនស្របច្បាប់** គឺជាសកម្មភាព ឬសេចក្តីសម្រេច ដែលអនុវត្តហួសពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា។ ដូច្នេះ នៅពេលអនុវត្តតួនាទី ភារកិច្ច របស់ខ្លួន ក្រុមប្រឹក្សា គណៈអភិបាល អភិបាល គណៈកម្មាធិការ និងបុគ្គលិកក្រុមប្រឹក្សាត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- រាល់សកម្មភាព ឬសេចក្តីសម្រេចទាំងឡាយណា ដែលខុសច្បាប់ សេចក្តីសម្រេច ឬសកម្មភាពនោះពុំមានសុពលភាព
- ការចំណាយដើម្បីអនុវត្តសកម្មភាព ឬសេចក្តីសម្រេចណាមួយ ដែលមិនស្របច្បាប់ គឺជាការចំណាយមិនស្របច្បាប់ ។ ឧទាហរណ៍ : ប្រធានក្រុមប្រឹក្សាប្រើប្រាស់ថវិកាមួយចំនួន សម្រាប់អនុវត្តសកម្មមួយ ក្នុងនាមក្រុមប្រឹក្សា ហើយដែលសកម្មភាពនោះមិនត្រូវបានអនុម័តដោយក្រុមប្រឹក្សា ដូច្នេះការចំណាយនោះ គឺជាការចំណាយមិនស្របច្បាប់ ។
- ជនណាដែលបានរងផលប៉ះពាល់ពីសកម្មភាព ឬសេចក្តីសម្រេចមិនស្របច្បាប់អាចទាមទារសំណងមកវិញឱ្យបានគ្រប់ចំនួន

- ករណីការចំណាយមិនស្របច្បាប់ដើម្បីអនុវត្តសេចក្តីសម្រេច ឬសកម្មភាពណាមួយ ដែលក្រុមប្រឹក្សា ឬគណៈអភិបាលទាំងមូលបានគាំទ្រ សមាជិកក្រុមប្រឹក្សា ឬគណៈអភិបាលម្នាក់ៗនោះត្រូវសងមកវិញឱ្យបានគ្រប់ចំនួនក្នុងចំណែកស្មើៗគ្នា
- បុគ្គលជាក់លាក់ណាមួយក្នុងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាដែលបានធ្វើការចំណាយមិនដើម្បីអនុវត្តសេចក្តីសម្រេច ឬសកម្មភាពរបស់ក្រុមប្រឹក្សា បុគ្គលនោះត្រូវ សងរាល់ការចំណាយទាំងនោះឱ្យបានគ្រប់ចំនួនមកវិញ។

☞ ដើម្បីចៀសវាងនូវការអនុវត្តសកម្មភាព ឬទង្វើដែលមិនស្របច្បាប់មុនពេលចេញដីកា ឬសេចក្តីសម្រេច ឬកិច្ចព្រមព្រៀងណាមួយ ដែលក្រុមប្រឹក្សា ឬគណៈអភិបាលយល់ឃើញថា ជាបញ្ហារសើប ឬមិនច្បាស់លាស់ អភិបាលក្នុងនាមក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួនអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញក្នុងរយៈពេលមួយ(០១)ខែបន្ទាប់ពីទទួលបានសំណើនោះ។ បញ្ហាទាំងឡាយណាដែលអាចចាត់ទុកថាជាបញ្ហារសើប ឬមិនច្បាស់លាស់ គឺអាស្រ័យទៅលើការពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាក្នុងអង្គប្រជុំក្រុមប្រឹក្សា ឬកិច្ចប្រជុំគណៈអភិបាល ដោយមានយោបល់ខ្វែងគ្នាជាច្រើន ដែលនាំឱ្យអង្គប្រជុំមិនអាចសម្រេចបានដោយសម្លេងភាគច្រើន ឬជាបញ្ហាដែលក្រុម





ប្រឹក្សា ឬគណៈអភិបាលយល់ឃើញថា ត្រូវតែសុំយោបល់ជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ឧទាហរណ៍ ដូចជា គម្រោងអភិវឌ្ឍន៍ដែលអាចមានផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ហើយក្រុមប្រឹក្សាមិនទាន់មានប្រព័ន្ធដោះស្រាយ ឬមានដែរ តែប្រព័ន្ធនោះមានលក្ខណៈមិនច្បាស់លាស់ ឬកិច្ចការណាមួយជាសំណូមពររបស់ប្រជាពលរដ្ឋ ប៉ុន្តែក្រុមប្រឹក្សា និងគណៈអភិបាលមានភាពមិនច្បាស់លាស់អំពីប្រព័ន្ធ និងនីតិវិធីដើម្បីដោះស្រាយ។

☞ ក្នុងករណីដែលសកម្មភាព ឬសេចក្តីសម្រេចដែលមិនស្របច្បាប់ត្រូវបានអនុវត្តរួចហើយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងគណៈអភិបាលអំពីសកម្មភាព ឬសេចក្តីសម្រេចមិនស្របច្បាប់ណាមួយនោះ។ ក្រោយពីទទួលបានការជូនដំណឹងជាលាយល័ក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា ឬគណៈអភិបាលត្រូវឆ្លើយបំភ្លឺតបវិញក្នុងរយៈពេលយ៉ាងយូរ(០១)ខែ ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរ (០១) ខែ បើសិនក្រសួងយល់ឃើញថា សកម្មភាព ឬសេចក្តីសម្រេចនោះនៅតែមិនស្របច្បាប់។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃត្រូវផ្តល់យោបល់ និងណែនាំដល់ក្រុមប្រឹក្សា និងគណៈអភិបាល អំពីវិធានការចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សា និងគណៈអភិបាលធ្វើសកម្មភាពនោះឱ្យស្របច្បាប់ឡើងវិញ។ ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមនូវការណែនាំ

របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទាក់ទងនឹងបញ្ហានេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ៣.២.២. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

យោងមាត្រា១១៤ គ្រប់ក្រុមប្រឹក្សាមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការយ៉ាងតិចចំនួន បី រួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និង
- គណៈកម្មាធិការលទ្ធកម្ម

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងៗបន្ថែមទៀត ដើម្បីជួយការងារក្រុមប្រឹក្សា ប៉ុន្តែមិនត្រូវមានតួនាទី ភារកិច្ច ត្រួតគ្នាជាមួយនឹងគណៈកម្មាធិការទាំងបីខាងលើឡើយ។

### ក). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

☞ **សមាសភាព**

- សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមាន :
  - អភិបាល ជាប្រធាន
  - ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា ជាសមាជិក
  - ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា ជាសមាជិក





  - ប្រធានមន្ទីរ/អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ជាសមាជិក
  - តំណាងផ្សេងៗទៀតតាមការចាំបាច់ ជាសមាជិក

☞ **តួនាទី ភារកិច្ច** គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវខិតខំធានាឱ្យបានថា រាល់ផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាល ដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋា រចនាសម្ព័ន្ធដោយផ្ទាល់ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបាន ដាក់បញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុង :

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ
- កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង
- គម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។

**បញ្ជាក់ :** សមាសភាព តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជាក់លាក់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅតាមថ្នាក់រដ្ឋបាលនីមួយៗនឹងកំណត់បន្ថែមទៀតដោយអនុក្រឹត្យ។

## ខ). គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

☞ **ការបង្កើត និងសមាសភាព** សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះ ឬស្ត្រី និងបុរសនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

☞ **តួនាទី ភារកិច្ច** គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានតួនាទី ភារកិច្ចដូចខាងក្រោម :

- ផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រីនិងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ដែលរបាយការណ៍នោះត្រូវរួមបញ្ចូលចំណុចមួយចំនួនដូចជា :
  - ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី ក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងស្ថានភាពរបស់កុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា





  - សមិទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
  - អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

**បញ្ជាក់ :** តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នឹងត្រូវកំណត់បន្ថែមទៀតដោយប្រកាស។

## គ). គណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្ម មានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពលទ្ធកម្ម ប្រព្រឹត្តទៅប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលសាមី និងប្រជាពលរដ្ឋរបស់ខ្លួន។

**បញ្ជាក់ :** តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈកម្មាធិការលទ្ធកម្មនឹងកំណត់បន្ថែមទៀតដោយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣.២.៣. គណៈអភិបាល

គណៈអភិបាល ជាសេនាធិការ ជាអ្នកអនុវត្តសេចក្តីសម្រេច និងជាអ្នកផ្តល់យោបល់ឱ្យក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### ក). តួនាទី និងភារកិច្ចគណៈអភិបាល

គណៈអភិបាលមានតួនាទី និងភារកិច្ចចម្បងៗមួយចំនួន ដូចខាងក្រោម :

- ត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- ត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាអំពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធាន ដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សា
- ជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានបែងចែក ឬបានផ្ទេរទៅឱ្យក្រុមប្រឹក្សា ហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពី របៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ





- ជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រាយការណ៍ជូនក្រុមប្រឹក្សាអំពី ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ក្រុមប្រឹក្សា
- ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលត្រូវមានវិធានការ ដើម្បីធានាឱ្យមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា បំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព
- ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី :
  - ការបង្កើត ឬរំសាយអង្គភាពរបស់ក្រុមប្រឹក្សា
  - ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
  - ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាម បទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា
  - ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការ

  កំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា
  - ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
  - ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន
- ជួយក្រុមប្រឹក្សាក្នុងការរៀបចំ និងដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តនូវ :
  - ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ
  - ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
  - កម្មវិធីវិនិយោគពាឆ្នាំរំកិលប្រចាំឆ្នាំ
  - គម្រោងថវិកាប្រចាំឆ្នាំ និង
  - របាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចការរបស់ក្រុមប្រឹក្សា ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- លើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើផែនការអភិវឌ្ឍន៍ និងលើបញ្ហាចាំបាច់ផ្សេងទៀតជាមួយ :
  - ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា





  - ក្រុមប្រឹក្សាប្រភេទផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល
  - ដៃគូពាក់ព័ន្ធដទៃទៀត។
- ពិគ្រោះយោបល់អំពីផែនការអភិវឌ្ឍន៍ និងបញ្ហាចាំបាច់ផ្សេងទៀតក្នុងនាមក្រុមប្រឹក្សា
- ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់ក្រុមប្រឹក្សា
- លើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សា ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលមានការរំលោភអំណាចកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាអំពីការបង្កើតគណៈកម្មាធិការនានាជាបន្ថែមទៀត តាមការចាំបាច់
- ត្រូវធានាឱ្យមានការបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយ

ព័ត៌មានផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន

- ត្រូវតែបិទផ្សាយឯកសារព័ត៌មាននៅលើក្តារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀត ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

## ខ). តួនាទី និងសិទ្ធិអំណាចរបស់អភិបាល

ក្រៅពីតួនាទី ភារកិច្ចសម្របសម្រួលក្នុងគណៈអភិបាលឱ្យសម្រេចបាននូវតួនាទី ភារកិច្ចរបស់គណៈអភិបាលដូចបានថែងខាងលើ ច្បាប់ក៏បានប្រគល់តួនាទី និងសិទ្ធិអំណាចជាក់លាក់មួយចំនួនបន្ថែមទៀតឱ្យអភិបាល រួមមាន :

- ជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ដើម្បីធានាឱ្យសេវា និងការអភិវឌ្ឍគ្រប់វិស័យឆ្លើយតបទៅនឹងការអភិវឌ្ឍមូលដ្ឋានសម្រាប់ជា គុណប្រយោជន៍ដល់ការចូលរួមលើកកម្ពស់គុណភាពរស់នៅ និងធានាបាននូវគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- ជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់





និងសិទ្ធិមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- នេះគឺជាមុខងារវិសហមជ្ឈការ ដែលបានធ្វើប្រតិភូកម្មជូនអភិបាល។ អភិបាល ត្រូវតែអនុវត្តតួនាទីនេះ ដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋាន និងការណែនាំ ដឹកនាំពីរាជរដ្ឋាភិបាល និងពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ ទោះបីអភិបាលមានតួនាទីជាក់លាក់ដូចនេះក្តី នៅក្នុងការអនុវត្ត អភិបាលត្រូវមានយន្តការពិគ្រោះ ពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួន និងសុំយោបល់ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ហើយត្រូវ តែរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីសកម្មភាពដែលបានអនុវត្តទាំងនោះ។

**បញ្ជាក់ :** តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់គណៈអភិបាលត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ក្នុងករណីចាំបាច់។

## ៣.២.៤. នាយករដ្ឋបាល

### ក). ការតែងតាំង

ក្រុមប្រឹក្សានីមួយៗត្រូវមាននាយករដ្ឋបាលមួយរូប ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ខ). តួនាទី ភារកិច្ចរបស់នាយករដ្ឋបាល

នាយករដ្ឋបាលមានតួនាទីជាជំនួយការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួនលើកិច្ចការសំខាន់ៗដូចខាងក្រោម :

- ចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាព កិច្ចការរដ្ឋបាលប្រចាំ

ផ្ទៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល

- ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីឱ្យគណៈអភិបាលអាចអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
- ធានាឱ្យប្រធានហិរញ្ញវត្ថុ បំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ។

ដូច្នេះ ក្នុងការចាត់ចែងការងារ នាយករដ្ឋបាលត្រូវស្ថិតនៅក្រោមការដឹកនាំ ណែនាំជាប្រចាំពីអភិបាល និងគណៈអភិបាលរបស់ខ្លួន ហើយត្រូវមានគណនេយ្យភាពដោយផ្ទាល់ ចំពោះអភិបាល និងគណៈអភិបាលរបស់ខ្លួន ។

**បញ្ជាក់ :** តួនាទី ភារកិច្ច និងរបៀបរបបធ្វើការលម្អិតរបស់នាយករដ្ឋបាលនឹងត្រូវកំណត់ដោយប្រកាសស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការរបស់នាយករដ្ឋបាល ។



៣. រចនាសម្ព័ន្ធ និងតួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ៣.២.៥. បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា

### ក). បុគ្គលិក

☞ ក្រុមប្រឹក្សានីមួយៗត្រូវមានបុគ្គលិករបស់ខ្លួន ។ បុគ្គលិកក្រុមប្រឹក្សារួមមានបីប្រភេទ គឺ :

- បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា (ឧ. ប្រធានហិរញ្ញវត្ថុ...)
- បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា (ឧ. នាយករដ្ឋបាល...) និង
- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា ស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ (ឧ. បុគ្គលិកដែលផ្ទេរពីក្រសួងស្ថាប័នឱ្យទៅជាបុគ្គលិករបស់ក្រុមប្រឹក្សា នៅពេលដែលមុខងារទាក់ទងនឹងបុគ្គលិកនោះ ត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សា) ។

☞ សមាជិកក្រុមប្រឹក្សាមិនមែនជាបុគ្គលិកក្រុមប្រឹក្សាឡើយ ។

### ខ). អង្គភាពរបស់ក្រុមប្រឹក្សា

យោងមាត្រា១៨៩, ១៩០, ១៩១ បានកំណត់ឱ្យ :

- ក្រុមប្រឹក្សាត្រូវមានអង្គភាពនានារបស់ខ្លួនតាមការចាំបាច់ ។ ក្រុមប្រឹក្សាត្រូវរៀបចំអង្គភាព កំណត់មុខងារ ភារកិច្ច និងរៀបចំមុខតំណែងបុគ្គលិកក្នុងអង្គភាពនានារបស់ខ្លួនឱ្យបានសមស្របតាមអនុក្រឹត្យ ដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

- អង្គភាពរបស់ក្រុមប្រឹក្សានីមួយៗត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ព្រមទាំងស្ថិតនៅក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព។

## ៣.២.៦. គណនេយ្យភាព

### ក). ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះ :

- ប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដែលបានសម្រេចដោយធានានូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។

### ខ). គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

គណៈកម្មាធិការនីមួយៗនៃក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន ប៉ុន្តែក្នុងរបៀបរបបការងារ និងទំនាក់ទំនងការងារគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀតទាត់ឱ្យក្រុមប្រឹក្សា និងគណៈអភិបាល។ ការធ្វើរបាយការណ៍ជូនគណៈអភិបាល ដើម្បីឱ្យគណៈអភិបាលធ្វើការបូកសរុបរបាយការណ៍តាម





ពេលវេលាកំណត់ជូនក្រុមប្រឹក្សា ឧទាហរណ៍ ប្រចាំត្រីមាស ឬប្រចាំឆ្នាំ។ល។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាក៏អាចចាត់ឱ្យគណៈកម្មាធិការនានារាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនបានដែរ ឬក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចបង្កើតឱ្យមានគណៈកម្មាធិការ ឬក្រុមការងារ ដើម្បីសិក្សាស្រាវជ្រាវលើករណីជាក់លាក់ណាមួយដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាផងដែរ។

### គ). គណៈអភិបាល

គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។

### ឃ). នាយករដ្ឋបាល

យោងមាត្រា១៨៤ នាយករដ្ឋបាលមានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។ ក្នុងតួនាទីនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះអភិបាលរបស់ខ្លួន និងដោយប្រយោលចំពោះក្រុមប្រឹក្សារបស់ខ្លួន។

### ង). អង្គភាព

អង្គភាពនីមួយៗត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព។ ប្រធានអង្គភាពនីមួយៗត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។

### ច). បុគ្គលិកក្រុមប្រឹក្សា

បុគ្គលិកទាំងអស់របស់ក្រុមប្រឹក្សា ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោល ចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម ។





# ៤. ទំនាក់ទំនងរវាងថ្នាក់រដ្ឋបាលនីមួយៗ

## ៤.១. ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់

ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី ជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី រួមមាន :

- ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារ ភារកិច្ចរបស់ខ្លួន ដែលថវិកានោះត្រូវស្ថិតនៅក្នុងថវិការាជធានី
- ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាខណ្ឌត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ
- ក្រុមប្រឹក្សារាជធានីត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចឱ្យក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**បញ្ជាក់ :** ទំនាក់ទំនងលម្អិតរវាងក្រុមប្រឹក្សារាជធានីជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ៤.២. ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់

ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង :

- ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ត្រូវមានថវិកាសម្រាប់អនុវត្តមុខងារភារកិច្ចរបស់ខ្លួន ដែលថវិកានោះត្រូវស្ថិតនៅក្នុងថវិកាក្រុង
- ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាក្រុងត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចឱ្យក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**បញ្ជាក់** : ទំនាក់ទំនងលម្អិតរវាងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ៤.៣. ទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់

ទំនាក់ទំនងរវាងក្រុមប្រឹក្សាខេត្ត ជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់រួមមាន :

- ក្រុមប្រឹក្សាខេត្តត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥) ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមការរៀបចំ





កម្មវិធីវិនិយោគបី(៣) ឆ្នាំរំកិលប្រចាំឆ្នាំរបស់ខ្លួន ដោយត្រូវពិគ្រោះយោបល់ជាមួយនឹងប្រភេទក្រុមប្រឹក្សាផ្សេងទៀត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចជា ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ជាដើម ។

- ក្រុមប្រឹក្សាខេត្ត អាចទទួលប្រតិភូកម្មពីក្រសួងមហាផ្ទៃក្នុងការជួយជំរុញឱ្យក្រុមប្រឹក្សាស្រុកធ្វើការរួមគ្នាជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ឱ្យស្របតាមខ្លឹមសារនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**បញ្ជាក់** : ទំនាក់ទំនងលម្អិតរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ៤.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក

ក្រុមប្រឹក្សាស្រុក ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងស្រុករបស់ខ្លួន ។ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវ :

- ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗឱ្យបង្កើត ជំរុញ និង

ធ្វើឱ្យមានចីរភាព សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

- រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជន នៅក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់
- ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់
- មានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកអំពីជម្រើស សេចក្តីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្តីសម្រេច និងការអនុវត្តទាំងនោះ
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងអ្នកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃឱ្យបានទៀងទាត់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងធ្វើការអប់រំ បណ្តុះបណ្តាលដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗឱ្យបានទៀងទាត់ ។
- សហការជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ដែលពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលយុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាព ដែលបាន





កំណត់ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការ និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ របស់ស្រុក និងរបស់ឃុំ សង្កាត់ ព្រមទាំងគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុក និងឃុំ សង្កាត់

- សម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬធនធានផ្នែករដ្ឋបាល ដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានសមត្ថភាពផ្នែករដ្ឋបាល ឬធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងជាអចិន្ត្រៃយ៍ ដើម្បី :
  - ជំរុញ ឬធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬបំពេញមុខងារ ភារកិច្ចចាំបាច់មួយ ឬច្រើន
  - បំពេញសមត្ថភាពផ្នែករដ្ឋបាល និងធនធានផ្នែករដ្ឋបាល រួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ និងសម្ភារៈចាំបាច់ នានា ។

## ៤.៥. ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.៥.១. គោលការណ៍ទូទៅ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានណែនាំអំពីការបែងចែកអំណាចដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិតាំងពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលកើតឡើងដោយការបោះឆ្នោតសកល និងអសកល គឺជាអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតក្នុងខ្សែរយៈនៃអំណាចនីតិប្រតិបត្តិ ។

ផ្អែកតាមគោលការណ៍នៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ ដែលកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានផ្តល់នូវស្វ័យភាពដល់រដ្ឋបាលទាំងនោះ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការចាត់ចែងកិច្ចការនានាក្នុងក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាន ប៉ុន្តែមិនមែនជាការផ្តល់អធិបតេយ្យភាពឡើយ ។

ប្រព័ន្ធអភិបាលកិច្ចថ្មីនៅថ្នាក់រដ្ឋបាលក្រោមជាតិនេះ បានតម្រូវឱ្យមានការកំណត់ឡើងវិញនូវទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមគោលការណ៍ដូចខាងក្រោម :

- កំណត់ក្របខ័ណ្ឌគោលនយោបាយ និងក្រខ័ណ្ឌច្បាប់សម្រាប់ការចាត់ចែងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបេបប្រជាធិបតេយ្យ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- តាមរយៈក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ទាំងនេះ





ថ្នាក់ជាតិត្រូវធ្វើការពិនិត្យឡើងវិញនូវមុខងារ និងធនធាន ដើម្បីប្រគល់មុខងារ និងធនធានសមស្របឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍ ដែលជាតម្រូវការអាទិភាពរបស់មូលដ្ឋាន សំដៅលើកកម្ពស់គុណភាពជីវិតសហ-គមន៍មូលដ្ឋាន ចូលរួមកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។
- កំណត់ស្តង់ដាសេវានានា ដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋដោយរដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្តល់ការគាំទ្រផ្នែកសមត្ថភាព ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវា និងការអភិវឌ្ឍជូនប្រជាពលរដ្ឋប្រកបដោយគុណភាព មានតម្លាភាព និងមានគណនេយ្យភាព ។
- ត្រួតពិនិត្យនីត្យានុកូលភាពទៅលើការសម្រេច និងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់តាមតម្រូវការនៃច្បាប់ ដើម្បីធានាឱ្យបានថារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមិនធ្វើការសម្រេច ឬធ្វើសកម្មភាពណាមួយដែលផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលនៅជាធរមាន ។
- ធ្វើការសម្រេចរំសាយក្រុមប្រឹក្សាណាមួយ ដែលធ្វើសកម្មភាពផ្ទុយ

ពីរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាន ដែលមានជាធរមាន បន្ទាប់ពីបានធ្វើអន្តរាគមន៍ឱ្យកែលម្អ មិនបានទទួលលទ្ធផលជាវិជ្ជមានមក។ ការធ្វើអន្តរាគមន៍ និងសម្រេចរំសាយក្រុមប្រឹក្សានេះ ត្រូវធ្វើឡើងតាមតែលក្ខខ័ណ្ឌដែលកំណត់ក្នុងច្បាប់តែប៉ុណ្ណោះ។

## ៤.៥.២. តួនាទីរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ

ផ្អែកតាមគោលការណ៍ទូទៅខាងលើនេះក្រសួង ស្ថាប័ននានាសុទ្ធតែមានតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួនក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ។

ក្នុងន័យនេះ មុខងារ និងការទទួលខុសត្រូវ ដែលបានចាត់ចែងដោយក្រសួង ស្ថាប័ននៅថ្នាក់ជាតិដោយផ្ទាល់ក្តី ឬតាមរយៈមន្ទីរ អង្គភាពជាខ្សែបណ្តោយរបស់ខ្លួនក្តី ប៉ុន្តែមុខងារ និងការទទួលខុសត្រូវនោះត្រូវបានផ្ទេរ ឬប្រគល់ជាមុខងារផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រគល់ទាំងភាពជាម្ចាស់លើមុខងារ និងការទទួលខុសត្រូវនោះហើយក៏ដោយ ក៏ក្រសួងស្ថាប័នសាមីនៅតែមានតួនាទីតាមដាន និងពិនិត្យមើលប្រសិទ្ធិភាព និងគុណភាពនៃការអនុវត្តមុខងារទាំងនោះ ដើម្បីឱ្យប្រាកដថារដ្ឋបាលថ្នាក់ក្រោមជាតិទទួលយកមុខងារ និងការទទួលខុសត្រូវទាំងនោះទៅបម្រើប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរបំផុត ។

ចំពោះមុខងារ និងការទទួលខុសត្រូវតាមបែបវិសហមជ្ឈការដែលបាន





ធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ននីមួយៗត្រូវផ្តល់ការណែនាំជាលាយលក្ខ័អក្សរអំពីបែបបទ នីតិវិធីរួមទាំងធនធាន និងសមត្ថភាពសម្រាប់អនុវត្តមុខងារ និងការទទួលខុសត្រូវនោះ ដើម្បីបម្រើប្រជាពលរដ្ឋក្នុងនាមក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មមុខងារនោះ។ ភាពជាម្ចាស់លើមុខងារ និងការទទួលខុសត្រូវនោះនៅតែជារបស់ក្រសួង ស្ថាប័នសាមីដដែល។

ដូច្នេះសរុបមកក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនានា គឺជាអង្គការតំណាងឱ្យផលប្រយោជន៏នៃប្រជាពលរដ្ឋនៅតាមថ្នាក់រដ្ឋបាលនីមួយៗផង និងជាតំណាងឱ្យផលប្រយោជន៏នៃរដ្ឋបាលថ្នាក់ជាតិ ពោលគឺតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលផងដែរ ។

## ៤.៥.៣. តួនាទីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្នុងការរៀបចំឡើងវិញនូវក្របខ័ណ្ឌទំនាក់ទំនង និងការកំណត់មុខងារការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការពាក់ព័ន្ធពីគ្រប់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ទាមទារឱ្យមានយន្តការសម្របសម្រួលមួយដើម្បីរៀបចំនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ច( ប្រព័ន្ធគ្រប់គ្រង) នៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ដែលគ្មានភាពប្រទាំងប្រទើសគ្នាពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀត ដើម្បីទាំងអស់គ្នាមានភាពងាយស្រួលក្នុងការគាំទ្រ និងប្រើប្រាស់ប្រព័ន្ធអភិបាលកិច្ចនេះ និង

ការគាំទ្រផ្នែកគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ការកសាងសមត្ថភាព ការអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

អាស្រ័យដោយសំណូមពរនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យបង្កើតគណៈកម្មាធិការជាតិមួយឈ្មោះថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលឈ្មោះជាអក្សរកាត់ថា " គ.ជ.អ.ប" ។

គណៈកម្មាធិការជាតិនេះ គឺជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការដឹកនាំសម្របសម្រួលការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិនេះមានតួនាទីចម្បងដូចខាងក្រោម :

- កំណត់មុខងារ និងការទទួលខុសត្រូវណា ដែលនឹងត្រូវផ្ទេរឱ្យក្រុមប្រឹក្សានៅតាមថ្នាក់នីមួយៗ ហើយមុខងារ និងការទទួលខុសត្រូវណាត្រូវរក្សាទុកនៅថ្នាក់ជាតិ
- ត្រូវធានាឱ្យបានថា ក្រុមប្រឹក្សាទទួលបានអ្វីៗចាំបាច់ រួមមាន ប្រាក់ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និង សមត្ថភាពសមស្របសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារ ដែលបានផ្ទេរទៅឱ្យ
- ក្នុងពេលរងចាំការផ្ទេរមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គ.ជ.អ.ប ត្រូវធានាឱ្យបានថា ក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិបានធ្វើសមាហរណកម្មនូវផែនការអភិវឌ្ឍ និងថវិការបស់ខ្លួននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍ និងថវិការបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ





- ត្រូវពិនិត្យមើលថា តើការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារជាក់លាក់ណាមួយឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយក្រុមប្រឹក្សានោះអនុវត្តមុខងារដែលបានផ្ទេរ មានប្រសិទ្ធិភាពឬទេ? ក្នុងករណីចាំបាច់ គ.ជ.អ.ប ត្រូវធ្វើការពិនិត្យ និងកែសម្រួលមុខងារដែលបានផ្ទេរនោះឡើងវិញ
- ត្រូវធានាឱ្យបានផងដែរថា សេចក្តីសម្រេចរបស់ខ្លួន ក៏ដូចជាសេចក្តីសម្រេចរបស់ក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលត្រូវបានអនុវត្ត។ ក្នុងករណីដែលក្រុមប្រឹក្សាណាមួយនៅថ្នាក់ក្រោម ជាតិមិនអនុវត្តតាម គ.ជ.អ.ប ត្រូវស្នើទៅក្រសួងមហាផ្ទៃឱ្យអនុវត្តនីតិវិធីដែលកំណត់ដោយច្បាប់រៀបចំអង្គការ។

ដើម្បីអនុវត្តតួនាទីចម្បងខាងលើនេះ គ.ជ.អ.ប មានអនុគណៈកម្មា-ធិការ និងលេខាធិការដ្ឋានមួយជាជំនួយការ។ កិច្ចការរបស់ក្រសួង ស្ថាប័ននានាដែលមានការពាក់ព័ន្ធដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកការសម្របសម្រួលជាមុន ក្នុងយន្តការនៃ គ.ជ.អ.ប ដើម្បីធានាថា យន្តការទាំងនោះត្រូវអនុវត្តស្របតាមគោលការណ៍នានា ដែលកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។

# ផ្នែកទី ២
# របៀបរបបគ្រប់គ្រងទូទៅ
# នៅរដ្ឋបាលថ្នាក់ក្រោមជាតិ





## ផ្នែកទី ២
## របៀបរបបគ្រប់គ្រងទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីធានាដល់ការចាប់ផ្តើមបំពេញការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន បន្ទាប់ពីការប្រកាសចូលកាន់តំណែង អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ :

- ចាត់តាំងមន្ត្រីសមស្របនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ របស់ខ្លួនឱ្យទទួលភារកិច្ចបន្ថែម ជាលេខាធិការដ្ឋានបណ្តោះអាសន្នរបស់ក្រុមប្រឹក្សារហូតដល់មានការរៀបចំជាថ្មី។ លេខាធិការដ្ឋានបណ្តោះអាសន្ននេះមានតួនាទី ភារកិច្ចជាជំនួយការទូទៅឱ្យក្រុមប្រឹក្សា ដែលក្នុងនោះមានជាអាទិ៍ :
    - រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំឱ្យដល់អ្នកដែលត្រូវអញ្ជើញចូលរួមប្រជុំ
    - រៀបចំទីកន្លែងប្រជុំ
    - រៀបចំសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំជូនក្រុមប្រឹក្សា ដើម្បីពិនិត្យ និងអនុម័ត
    - រៀបចំ តាក់តែងឯកសារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សា
    - ទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- បែងចែកភារកិច្ចជូនអភិបាលរងនានាតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- សម្របសម្រួលការងារប្រចាំថ្ងៃក្នុងរដ្ឋបាលរបស់ខ្លួនស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។
- ដឹកនាំគណៈអភិបាលរបស់ខ្លួន និងមន្ត្រីអង្គភាពនានាក្រោមឱវាទ អនុវត្តសកម្មភាពរបស់រដ្ឋបាលខ្លួន តាមការសម្រេចរបស់ក្រុមប្រឹក្សា រួមទាំងការត្រៀមរៀបចំ និងការអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សាខ្លួន។

ក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ក្រុមប្រឹក្សាគួរផ្តោតការយកចិត្តទុកដាក់លើកិច្ចការមួយចំនួនដូចជា :

- កិច្ចការរដ្ឋបាល
- ការគ្រប់គ្រងបុគ្គលិក
- ការគ្រប់គ្រងទ្រព្យសម្បត្តិ
- ការគ្រប់គ្រងហិរញ្ញវត្ថុ
- ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

## ១. ផ្នែកកិច្ចការរដ្ឋបាល

បន្ទាប់ពីកិច្ចប្រជុំប្រកាសចូលកាន់ដំណែង ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក អង្គភាពពាក់ព័ន្ធទាំងអស់ត្រូវគិតពិចារណា និងអនុវត្តកិច្ចការរដ្ឋបាលសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការទុកដាក់ឯកសារ





- ការរៀបចំប្រជុំ
- កិច្ចការប្រចាំថ្ងៃផ្សេងៗទៀត

### ១.១. ការរៀបចំទុកដាក់ឯកសារ

រាល់ឯកសារទាំងអស់ដែលគ្រប់គ្រងដោយរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌកន្លងមក ត្រូវបន្តគ្រប់គ្រងដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមី ក្រោយការចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។ ក្រុមប្រឹក្សាត្រូវទទួលខុសត្រូវលើឯកសារទាំងនោះ ដោយត្រូវប្រគល់ភារកិច្ចដល់គណៈអភិបាលឱ្យធ្វើការគ្រប់គ្រងឯកសារទាំងនោះឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។ គណៈអភិបាល ត្រូវធ្វើការណែនាំដល់មន្ត្រីទទួលខុសត្រូវទុកដាក់ឯកសារ ដោយត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- ឯកសារទាំងអស់ត្រូវរៀបចំទុកដាក់ និងថែរក្សាឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព
- ការរៀបចំទុកដាក់ឯកសារ អាចធ្វើឡើងតាមវិធីសាស្ត្រផ្សេងៗដូចជា :
  - **ការរៀបចំទុកដាក់តាមប្រភេទ** : មានន័យថា ត្រូវរៀបចំទុកដាក់ឯកសារតាមប្រភេទនៃឯកសារនីមួយៗ។ ឧទាហរណ៍:
    + ប្រភេទទី១ : លិខិតបទដ្ឋាននានា
    + ប្រភេទទី២ : កំណត់ហេតុប្រជុំ

+ ប្រភេទទី៣ : សំណុំឯកសារដេញថ្លៃ
+ ប្រភេទទី៤ : ឯកសារអំពីការគ្រប់គ្រងបុគ្គលិក
+ ...។ល។

- **ការទុកដាក់តាមកាលប្បវត្តិ** : មានន័យថា ជាការរៀបចំទុក ដាក់ឯកសារតាមកាលបរិច្ឆេទនៃឯកសារនីមួយៗ។

ឧទាហរណ៍ :

+ ឆ្នាំ ២០០៩ : រាល់ឯកសារដែលរៀបចំបង្កើត និងទទួលបានក្នុងឆ្នាំ២០០៩ ត្រូវទុកមួយដោយឡែក។
+ ឆ្នាំ២០០៨ : រាល់ឯកសារដែលរៀបចំបង្កើត និងទទួលបានក្នុងឆ្នាំ២០០៨ ត្រូវទុកមួយដោយឡែក។
+ ...។ល។

- **ការទុកដាក់ឯកសារតាមឈ្មោះ** : មានន័យថា រាល់ឯកសារទាំងអស់ត្រូវរៀបចំ ទុកដាក់តាមឈ្មោះបុគ្គល ឬឈ្មោះស្ថាប័ន។

ឧទាហរណ៍ :

+ ឯកសារស្រុក "ក"
+ ឯកសារស្រុក "ខ"

- **ការទុកដាក់ឯកសារតាមអក្ខរក្រម** : មានន័យថា ជាការទុកដាក់ឯកសារតាមលំដាប់នៃតួអក្សរ "ក-ខ-គ..."។





• ក្នុងការរៀបចំទុកដាក់ឯកសារ ត្រូវទុកដាច់ដោយឡែកពីគ្នារវាងឯកសារផ្ទៃក្នុង (មិនផ្សព្វផ្សាយជាសាធារណៈ) និងឯកសារសម្រាប់ផ្សព្វផ្សាយជាសាធារណៈ។

## ១.២. ការរៀបចំកិច្ចប្រជុំ

### ក). កិច្ចប្រជុំសាមញ្ញលើកទី១

ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំសាមញ្ញលើកទី១ មិនឱ្យហួសពី១៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា។

កិច្ចប្រជុំសាមញ្ញលើកទី១របស់ក្រុមប្រឹក្សា គឺជាកិច្ចប្រជុំផ្សព្វផ្សាយ និងស្តាប់របាយការណ៍លើបញ្ហា ដូចខាងក្រោម :

• **ទីមួយ** : ការផ្សព្វផ្សាយអំពីសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា និងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ ដូច្នេះអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យថតចម្លងឯកសារនេះជូនគ្រប់សមាជិកក្រុមប្រឹក្សា ដោយភ្ជាប់ជាមួយលិខិតអញ្ជើញប្រជុំ។

• **ទីពីរ** : ការផ្តួចផ្តើមរៀបចំសេចក្តីព្រាងប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២។

• **ទីបី** : អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍

អំពីស្ថានភាពនៃការទទួលបន្តអនុវត្តការងារនៃរដ្ឋបាលរបស់ខ្លួន ចាប់ពីថ្ងៃចូលកាន់តំណែងរហូតមកដល់កិច្ចប្រជុំសាមញ្ញលើកទី១នេះ។

- **ទីបួន :** បញ្ហាផ្សេងៗ។

ដោយសារមិនទាន់មានបទបញ្ជាផ្ទៃក្នុង ហេតុនេះក្រុមប្រឹក្សាមិនត្រូវអនុម័តបញ្ហាណាមួយក្នុងកិច្ចប្រជុំសាមញ្ញលើកទី១នេះឡើយ។

## ខ). កិច្ចប្រជុំសាមញ្ញលើកទី២

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន ក្រុមប្រឹក្សាត្រូវអនុម័តឱ្យបាននូវឯកសារដូចខាងក្រោម :

- ដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន
- ប្រតិទិននៃកិច្ចប្រជុំសាមញ្ញសម្រាប់រយៈពេលដប់ពីរ(១២)ខែ រាប់ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២នេះទៅ
- ផែនការសកម្មភាពរបស់ខ្លួនរយៈពេលបី(០៣)ខែ ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២នេះទៅ។

នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១ ក្រុមប្រឹក្សាត្រូវចាត់វិធានការ ដើម្បីណែនាំឱ្យមានការត្រៀមរៀបចំកិច្ចការចាំបាច់មួយចំនួន ដូចរៀបរាប់ខាងលើ ដើម្បីអាចយកទៅពិនិត្យ និងអនុម័ត នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន។ កិច្ចការចាំបាច់ទាំងនោះ រួមមាន ដូចជា :





- ការរៀបចំកន្លែងប្រជុំ និងលិខិតអញ្ជើញ
- ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា
- ការពិនិត្យគំរូបទបញ្ជាផ្ទៃក្នុង និងការផ្តួចផ្តើមរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។

ក្រុមប្រឹក្សា ត្រូវអនុវត្តកិច្ចប្រជុំសាមញ្ញរបស់ខ្លួនឱ្យបានទៀតទាត់ទៅតាមកាលបរិច្ឆេទ ដែលបានកំណត់ក្នុងប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន។

## ១.៣. កិច្ចការប្រចាំថ្ងៃផ្សេងៗទៀត

ក្រៅពីការរៀបចំទុកដាក់ឯកសារ និងការរៀបចំប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវដឹកនាំគណៈអភិបាលឱ្យចាត់វិធានការ ដើម្បីធ្វើការណែនាំឱ្យបុគ្គលិកទាំងអស់របស់ក្រុមប្រឹក្សា បន្តអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ខ្លួនជាធម្មតា រហូតដល់មានការរៀបចំជាថ្មីឡើងវិញ។ ក្រៅពីនេះ ក្រុមប្រឹក្សាត្រូវយកចិត្តទុកដាក់ពិនិត្យ និងចាត់ឱ្យគណៈអភិបាលរៀបចំឱ្យបានល្អនូវកិច្ចការចាំបាច់មួយចំនួនថែមទៀត ដូចជា :

- ការរៀបចំក្តារព័ត៌មាន
- ការចាត់វិធានការផ្សព្វផ្សាយព័ត៌មាន ជាសាធារណៈ
- ការរៀបចំការិយាល័យ និងសម្ភារៈការិយាល័យ
- ការរៀបចំសាលប្រជុំរបស់ក្រុមប្រឹក្សា
- ការរៀបចំលេខាធិការដ្ឋានបណ្តោះអាសន្នរបស់ក្រុមប្រឹក្សា

- ការទំនាក់ទំនងជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ
- ... ។ល ។

**បញ្ជាក់ :** ចំណាយទាំងអស់សម្រាប់កិច្ចប្រជុំ និងការបំពេញការងារនៃក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ គឺជាបន្ទុកនៃថវិការដ្ឋបាលរាជធានី ខេត្ត ក្នុងពេលដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនទាន់មានថវិកាផ្ទាល់របស់ខ្លួន។

## ២. ផ្នែកគ្រប់គ្រងបុគ្គលិក

☞ មាត្រា២៨១ បានកំណត់ថា អង្គភាព មន្ត្រី បុគ្គលិកដែលបំពេញការងារក្នុងអង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តជាអង្គភាព និងជាមន្ត្រីបុគ្គលិកនៃអង្គភាពទាំងនោះ របស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំជាថ្មី។ ហេតុនេះ អង្គភាព និងមន្ត្រីរាជការទាំងអស់ដែលបាននឹងកំពុងបម្រើការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មុនពេលចូលកាន់តំណែងរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នឹងបន្តស្ថិតនៅក្នុងស្ថានភាពដដែលដោយពុំមានការផ្លាស់ប្តូរអ្វីឡើយរហូតដល់មានការណែនាំស្តីពីការរៀបចំជាថ្មីឡើងវិញ។ ដោយឡែក អង្គភាព និងមន្ត្រីរាជការទាំងនេះ ត្រូវខិតខំបំពេញការងារមួយចំនួនថែមទៀត ដែលតម្រូវដោយក្រុមប្រឹក្សាដែលចូលកាន់តំណែង ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចចាប់ផ្តើមកិច្ចការ





នានារបស់ខ្លួន ប្រកបដោយភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។

☞ ក្រុមប្រឹក្សានីមួយៗ ត្រូវមានបុគ្គលិកក្រុមប្រឹក្សារបស់ខ្លួន។ បុគ្គលិកក្រុមប្រឹក្សាមិនត្រូវរាប់បញ្ចូលនូវមន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬមន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងនាមរាជរដ្ឋាភិបាលឡើយ។ ដូចនេះ ដើម្បីឱ្យក្រុមប្រឹក្សាចាត់ចែងកិច្ចការនានា សំដៅបន្តនិរន្តរភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ត្រីរាជការនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ទុកជាបុគ្គលិករបស់ក្រុមប្រឹក្សា ក្នុងល័ក្ខខ័ណ្ឌនៃការធ្វើប្រតិភូកម្មពីរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ។

☞ បុគ្គលិករបស់ក្រុមប្រឹក្សាត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ដូច្នេះគណៈអភិបាលត្រូវគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សាដោយផ្ទាល់ និងធ្វើជាសេនាធិការ ឱ្យក្រុមប្រឹក្សាក្នុងការផ្តល់អានុសាសន៍ទាក់ទងនឹង :

- ការបង្កើត ឬរំសាយអង្គភាព
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការតម្លើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិកដោយផ្អែកតាមបទបញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់

ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា

- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន។

ដើម្បីអនុវត្តគោលការណ៍ខាងលើនេះ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវផ្អែកតាមច្បាប់ និងលិខិតបទដ្ឋាននានា ដែលនៅជាធរមានរហូតដល់មានច្បាប់ លិខិតបទដ្ឋានថ្មីមកជំនួស។

☞ ដើម្បីគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សាឱ្យបានត្រឹមត្រូវ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- ការជ្រើសរើស និងតែងតាំងបុគ្គលិកដោយក្រុមប្រឹក្សាត្រូវដំណើរការតាមការប្រកួតប្រជែង និងមានតម្លាភាព
- ក្នុងដំណើរការជ្រើសរើស និងតែងតាំងបុគ្គលិករបស់ក្រុមប្រឹក្សាត្រូវធានាឱ្យមានចំនួនស្ត្រីសមស្របនៅមុខតំណែងប្រធាន ឬអនុប្រធានអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការជ្រើសរើស និងការតែងតាំងបុគ្គលិកត្រូវធ្វើឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ





- ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតសម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន
- ការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរបស់បុគ្គលិកក្រុមប្រឹក្សា ត្រូវធ្វើឡើងឱ្យស្របទៅតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

☞ បុគ្គលិកក្រុមប្រឹក្សាទាំងអស់ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានគ្រប់គ្រងផ្ទាល់របស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

## ៣. ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ

☞ ដើម្បីធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានលទ្ធភាពអនុវត្តមុខងារភារកិច្ចរបស់ខ្លួន ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាទទួលបាននូវទ្រព្យសម្បត្តិចាំបាច់នានា ដែលហៅថាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ គឺជាទ្រព្យសម្បត្តិ ដែលបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ។

ក្នុងពេលដែលមិនទាន់មានច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចការនានាដែលទាក់ទងនឹងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានដែលមានជាធរមាន ។

☞ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ក្រុមប្រឹក្សា គណៈភិបាល និងអ្នកពាក់ព័ន្ធត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវថែរក្សាការពារទ្រព្យសម្បត្តិ ដែលរដ្ឋប្រគល់ឱ្យ ហើយត្រូវគ្រប់គ្រងឱ្យមានប្រសិទ្ធភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិ គ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ
- ក្រុមប្រឹក្សាត្រូវរៀបចំគម្រោងថែទាំទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ





- ក្រុមប្រឹក្សាត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- ការត្រួតពិនិត្យ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមខ្លឹមសារ ដែលកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ៤. ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ

យោងតាមមាត្រា ២៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុសមស្របដើម្បី :

- គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន
- ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន
- អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## ៤.១. ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

☞ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ថវិការាជធានី ថវិកាខេត្ត ថវិកាក្រុង និងថវិកាស្រុក។ ខណ្ឌ និងសង្កាត់ចំណុះរាជធានីត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី។ សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង។

☞ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរួមចំណែកដល់ការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

## ៤.២. ប្រភពចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

☞ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកមានសិទ្ធិទទួលបានចំណូលពី :

- ប្រភពនៅមូលដ្ឋាន
- ប្រភពពីថ្នាក់ជាតិ និង
- ប្រភពផ្សេងៗទៀត។

### ក). ចំណូលពីប្រភពនៅមូលដ្ឋាន

☞ ចំណូលពីប្រភពនៅមូលដ្ឋានរួមមាន :

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត
- អំណោយស្ម័គ្រចិត្ត





- ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃ ដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក។ ការបែងចែកនេះត្រូវអនុវត្តតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

☞ ពន្ធ និងអាករនៅថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីច្បាប់សារពើពន្ធ។

### ខ). ចំណូលពីថ្នាក់ជាតិ

ចំណូលពីថ្នាក់ជាតិ រួមមាន :

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិការដ្ឋ និង
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

## ៤.៣. ការផ្ទេរមូលនិធិពីថវិការដ្ឋ

ក្រុមប្រឹក្សាមានសិទ្ធិទទួលចំណូលពីថ្នាក់ជាតិនូវមូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិផ្ទេរដោយគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ។

## ក). មូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ

មូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ :

- ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬច្រើនដែលត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា តាមការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬច្រើន ដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬច្រើនដែលបានកំណត់ ។

## ខ). មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ

មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បី :

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា ។





# ៤.៤. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ។

## ក). ការរៀបចំថវិកា

- គណៈអភិបាលមានភារកិច្ចក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ។
- ក្នុងការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងចំណូល និងចំណាយ ។

## ខ). ការពិនិត្យ និងអនុម័ត

តាមរយៈកិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តលើ :

- គម្រោងថវិកាប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហា និងការដោះស្រាយបញ្ហាហិរញ្ញវត្ថុដែលកើតមានឡើង
- របាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវធ្វើឡើងមិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ។

## គ). ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់

- អភិបាល គឺជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន
- ក្រុមប្រឹក្សា ត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុត រួមមាន :
  - តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ច និងធនធានថ្មីៗ
  - សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈមូលដ្ឋាន និងចាំបាច់
  - ការកាត់បន្ថយភាពក្រីក្រ
  - តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះ ដោយរាប់បញ្ចូលទាំងជនក្រីក្រ និងជនជាតិដើមភាគតិច ។
- ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកា ក្រុមប្រឹក្សាត្រូវធានានូវការអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :
  - ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា
  - គណនេយ្យ និងរបាយការណ៍
  - ទ្រព្យសកម្ម និងទ្រព្យអកម្ម





  - តម្លាភាព និងគណនេយ្យភាព
  - ការគ្រប់គ្រង :
    + ចំណូលផ្ទាល់
    + ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល
    + ចំណូលពីប្រភពផ្សេងៗទៀត
  - លទ្ធកម្មសាធារណៈ
  - ការធ្វើសវនកម្មផ្ទៃក្នុង
  - ការធ្វើសវនកម្មផ្ទៃក្រៅ
  - តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

**បញ្ជាក់ :**

- ក្រុមប្រឹក្សាគ្មានសិទ្ធិខ្ចីប្រាក់ បោះផ្សាយសញ្ញាប័ណ្ណ ឬ/និងមូលប័ត្រធានាគ្រប់កិច្ចសន្យា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយ ដែលនាំឱ្យកើតជាបំណុលឡើយ ។
- បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

# ៥. ផ្នែកកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

> យោងតាមមាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ។

## ៥.១. ចំណុចសំខាន់ៗនៃផែនការអភិវឌ្ឍន៍

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍន៍ ដោយផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម :

- **ចក្ខុវិស័យរបស់ក្រុមប្រឹក្សា** ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍ** ដោយធ្វើការប៉ាន់ស្មានអំពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :
  - តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ
  - សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា





  - ការកាត់បន្ថយភាពក្រីក្រ
  - តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច។
- **ក្របខ័ណ្ឌអភិវឌ្ឍន៍** ដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋាន ពិសេសក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ
- **ផែនការហិរញ្ញវត្ថុ** ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍន៍មូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី(៣)ឆ្នាំ ចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- **យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍន៍** ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផែនការគ្រប់គ្រងគ្រោះមហន្តរាយ
- សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍន៍នីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍន៍។

## ៥.២. អ្នកពាក់ព័ន្ធសំខាន់ៗ និងតួនាទី ភារកិច្ច

អ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរួមមានដូចខាងក្រោម :

### ក). គណៈអភិបាល

ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគជាកិច្ចការ ដែលទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ព្រមទាំងក្រុមប្រឹក្សានានាដែលពាក់ព័ន្ធ។ អនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនឹងចែងអំពីយន្តការនានាសម្រាប់ធានាឱ្យមានការចូលរួមខាងលើនេះ។ ក្នុងដំណើរការនេះ គណៈអភិបាលមានតួនាទី ភារកិច្ចដូចខាងក្រោម :

- ធ្វើជាសេនាធិការឱ្យក្រុមប្រឹក្សាក្នុងការរៀបចំ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិនិត្យ និងអនុម័តនូវ :
  - ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។
  - កម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ។
- លើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើផែនការអភិវឌ្ឍន៍ និងលើបញ្ហាចាំបាច់ផ្សេងទៀតជាមួយ :





  - ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
  - ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
  - ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល
  - ដៃគូពាក់ព័ន្ធដទៃទៀត
- ពិគ្រោះយោបល់អំពីផែនការអភិវឌ្ឍន៍ និងបញ្ហាចាំបាច់ផ្សេងទៀតជាមួយអ្នកពាក់ព័ន្ធ ក្នុងនាមក្រុមប្រឹក្សា
- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់ក្រុមប្រឹក្សា។

### ខ). គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវធានាឱ្យបានថាផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាល ដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានដាក់បញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា តាមនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីដំណើរការ កសាងផែនការអភិវឌ្ឍន៍

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**គ). ក្រុមប្រឹក្សា**

ក្រុមប្រឹក្សាមានតួនាទី ភារកិច្ចក្នុងការ :

- ទទួលខុសត្រូវរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលប្រចាំឆ្នាំ
- ពិនិត្យ និងអនុម័តលើផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ
- ពិនិត្យ និងអនុម័តលើកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ
- ពិនិត្យ និងអនុម័តលើដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍន៍ បន្ទាប់ពីបានអនុម័តហើយភ្លាម ។

**បញ្ជាក់ :** បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។



# ផ្នែកទី ៣
# ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា

# ផ្នែកទី ៣
# ការរៀបចំបទបញ្ជាផ្ទៃរបស់ក្នុងក្រុមប្រឹក្សា

## ១. អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង

បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការប្រកាសឈ្មោះប្រធានក្រុមប្រឹក្សា ក្រុមប្រឹក្សានៅតាមថ្នាក់រដ្ឋបាលនីមួយៗត្រូវត្រៀមរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។

ក្រោយអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងយូរ១៥ថ្ងៃ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំសាមញ្ញលើកទី១របស់ខ្លួន (ដោយសារមានកិច្ចការជាច្រើនដែលត្រូវអនុវត្តក្នុងឆ្នាំ២០០៩នេះ ជាការល្អក្រុមប្រឹក្សាអាចបើកកិច្ចប្រជុំសាមញ្ញលើកទី១ក្នុងរយៈពេលពីរទៅបីថ្ងៃ បន្ទាប់ពីកិច្ចប្រជុំចូលកានតំណែងក៏បាន) ដែលកិច្ចប្រជុំនេះ ធ្វើឡើងដើម្បី :

- ផ្សព្វផ្សាយអំពីសេចក្ដីណែនាំ របស់ក្រសួងមហាផ្ទៃស្ដីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា និងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- ការផ្ដួចផ្ដើមរៀបចំសេចក្ដីព្រាងប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសម្រាប់រយៈពេលដប់ពីរ(១២)ខែ





- ស្ដាប់របាយការណ៍របស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីស្ថានភាពនៃការទទួលបន្តអនុវត្តការងារ នៃរដ្ឋបាលរបស់ខ្លួន ចាប់ពីថ្ងៃចូលកាន់តំណែងរហូតមកដល់កិច្ចប្រជុំសាមញ្ញលើកទី១នេះ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើតាមទម្រង់ជាដីកា និងត្រូវអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬលើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១ឡើយ។

ដើម្បីសម្រេចបានកិច្ចការនេះ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី១ ក្រុមប្រឹក្សាត្រូវចាត់វិធានការណែនាំឱ្យសមាជិកម្នាក់ៗ ពិនិត្យខ្លឹមសារគំរូបទបញ្ជាផ្ទៃក្នុង បន្ទាប់ពីកិច្ចប្រជុំរួច ដើម្បីពិចារណាថាតើខ្លឹមសារត្រង់ណាគួររក្សាទុក ហើយខ្លឹមសារត្រង់ណាដែលត្រូវធ្វើការផ្លាស់ប្ដូរ ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងនៅតាមមូលដ្ឋានរៀងៗខ្លួន។ ប៉ុន្តែ ការកែសម្រួលផ្លាស់ប្ដូរនោះមិនត្រូវឱ្យផ្ទុយពីរដ្ឋធម្មនុញ្ញ និងច្បាប់ឡើយ។ ខ្លឹមសារដែលស្នើផ្លាស់ប្ដូរ ឬកែប្រែ ត្រូវយកមកពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទីពីរ។ យោងតាមមាត្រា៧១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាអាចអនុម័តយកគំរូបទបញ្ជាផ្ទៃក្នុង តាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដោយមាន ឬដោយមិនមានការកែប្រែ។

ក្នុងកិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវណែនាំគណៈអភិបាលដើម្បីចាត់តាំងមន្ត្រី ឱ្យធ្វើកំណត់ហេតុអង្គប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងឱ្យបានត្រឹមត្រូវ។ ក្រោយពីបានអនុម័តរួចហើយ ត្រូវរៀបចំចម្លងបទបញ្ជាផ្ទៃក្នុងនេះ ដើម្បីចែកជូនគ្រប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ញើជូនក្រសួងមហាផ្ទៃ និងរក្សាទុកជាឯកសារ។ ក្នុងករណីមានការកែប្រែ ក្រសួងមហាផ្ទៃនឹងពិនិត្យមើលអំពីខ្លឹមសារនៃការកែប្រែនោះ។ ក្នុងករណីខ្លឹមសារនៃការកែប្រែនោះផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានដែលនៅជាធរមាន ក្រសួងមហាផ្ទៃនឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សានោះ ធ្វើការកែតម្រូវឡើងវិញជាបន្ទាន់។ ក្រោយពីបានទទួលការណែនាំពីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាត្រូវធ្វើការកែតម្រូវឡើងវិញនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញបន្ទាប់។

## ២. ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុង

ដើម្បីឱ្យក្រុមប្រឹក្សាមានមូលដ្ឋានក្នុងការរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ក្រសួងមហាផ្ទៃបានរៀបចំសេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់ជាមួយគំរូបទបញ្ជាផ្ទៃក្នុង ហើយដែលសេចក្តីណែនាំនេះបានទទួលការអនុម័ត ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩។





គំរូបទបញ្ជាផ្ទៃក្នុងនេះ គឺជាឯកសារមូលដ្ឋានសម្រាប់ឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពិនិត្យពិចារណា និងរៀបចំនូវបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុងនេះបានចែងនូវលក្ខខណ្ឌ និងវិធានទាំងឡាយសម្រាប់ដំណើរការប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ ផ្អែកតាមគំរូបទបញ្ជាផ្ទៃក្នុងនេះ ក្រុម ប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចធ្វើការពិនិត្យ ឬកែលម្អបំពេញបន្ថែមឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមីរៀងៗខ្លួន និងឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីដាក់ចេញជាបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

### ២.១. ពាក្យគន្លឹះ

នៅក្នុងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ដែលណែនាំដោយក្រសួងមហាផ្ទៃ មានពាក្យគន្លឹះមួយចំនួន ដែលគួរស្វែងយល់ជាមុន :

- **បទបញ្ជាផ្ទៃក្នុង** : គឺជាវិធាន គោលការណ៍ច្បាប់ផ្ទៃក្នុង ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសម្រាប់កំណត់របៀបរបបធ្វើការងារ ការរៀបចំ និងដំណើរការប្រជុំរបស់ក្រុមប្រឹក្សា។
- **ក្រុមប្រឹក្សា** : សំដៅលើការជួបជុំសមាជិកក្រុមប្រឹក្សា ដើម្បីប្រជុំសាមញ្ញក្តី ឬវិសាមញ្ញក្តី ដើម្បីធ្វើការសម្រេចលើកិច្ចការដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយការជួបប្រជុំនោះមាន

លក្ខណៈត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ ដូចនេះ សកម្មភាពរបស់ក្រុមប្រឹក្សាគឺជាសកម្មភាពទាំងឡាយណាដែលធ្វើឡើងក្នុងនាមក្រុមប្រឹក្សាក្រោយពីបានការអនុម័តនៅក្នុងកិច្ចប្រជុំជាផ្លូវការរបស់ក្រុមប្រឹក្សា។ សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយសមាជិកក្រុមប្រឹក្សាណាម្នាក់ ហើយដែលសកម្មភាពនោះមិនមានការអនុម័តនៅក្នុងកិច្ចប្រជុំផ្លូវការរបស់ក្រុមប្រឹក្សាទេ សកម្មភាពនោះមិនមែនជារបស់ ឬក្នុងនាមក្រុមប្រឹក្សាឡើយ។

- **ក្រុមប្រឹក្សាប្រភេទរួមគ្នា :** ជាក្រុមប្រឹក្សាដែលស្ថិតនៅលំដាប់ថ្នាក់រដ្ឋបាលដូចៗគ្នា។ ឧ. ក្រុមប្រឹក្សាក្រុងទាំង២៦ជាក្រុមប្រឹក្សាប្រភេទរួមគ្នា ក្រុមប្រឹក្សាស្រុកចំនួន១០ជាក្រុមប្រឹក្សាប្រភេទរួមគ្នា។
- **ក្រុមប្រឹក្សាប្រភេទផ្សេងៗគ្នា :** ជាក្រុមប្រឹក្សាដែលស្ថិតនៅលំដាប់ថ្នាក់រដ្ឋបាលខុសៗគ្នា។ ឧ. ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ជាក្រុមប្រឹក្សាប្រភេទផ្សេងៗគ្នា។
- **កិច្ចប្រជុំសាមញ្ញ :** គឺជាកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដែលត្រូវធ្វើឡើងជាទៀតទាត់ មានកំណត់ប្រតិទិនច្បាស់លាស់ដោយក្រុមប្រឹក្សា ហើយដែលកិច្ចប្រជុំនីមួយៗត្រូវធ្វើឡើងមិនឱ្យមុន២៥ថ្ងៃ និង មិនលើសពី៣៥ថ្ងៃនៃកិច្ចប្រជុំសាមញ្ញលើកមុនរបស់ក្រុមប្រឹក្សា។ កិច្ចប្រជុំសាមញ្ញ ត្រូវធ្វើឡើងយ៉ាងហោចណាស់១២ដង





ជារៀងរាល់ឆ្នាំ។

- **កិច្ចប្រជុំវិសាមញ្ញ :** គឺជាការប្រជុំពិសេសរបស់ក្រុមប្រឹក្សា ដែលត្រូវធ្វើឡើងដើម្បីដោះស្រាយករណីបន្ទាន់ ឬពិសេសណាមួយ។ ចំនួនដងនៃការប្រជុំប្រភេទនេះ មិនកំណត់ឡើយ គឺអាស្រ័យតាមស្ថានភាព និងតម្រូវការជាក់ស្តែង។
- **ដីកា :** គឺជាសេចក្តីសម្រេចខាងបញ្ញត្តិ ដែលជាវិធានខាងផ្លូវច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើនិន្នាការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សា សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **សេចក្តីសម្រេច :** គឺជាសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ ដែលសេចក្តីសម្រេចទាំងនោះធ្វើឡើងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។
- **មុខងារជាកាតព្វកិច្ច :** គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស។
- **មុខងារជាជម្រើស :** គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច។

- **ទ្រព្យសម្បត្តិ** : ក្នុងន័យទូទៅគឺសំដៅទៅលើគ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យ លិខិត-ស្នាមឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អាគារ ព្រៃក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នា។
- **ផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ** : គឺជាការរៀបចំទស្សនវិស័យរយៈពេលវែង និងយុទ្ធសាស្ត្រក្នុងការងារអភិវឌ្ឍន៍របស់ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាប្រើប្រាស់ផែនការអភិវឌ្ឍន៍នេះ សម្រាប់ជាមូលដ្ឋានដើម្បីវិភាជន៍ធន-ធានដែលមាន ដើម្បីផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ និងសម្រាប់ជាក្របខ័ណ្ឌមួយដើម្បីកៀរគរធនធានបន្ថែមដើម្បីអភិវឌ្ឍន៍ សម្រាប់ធានានិរន្តរភាពប្រតិបត្តិការជាដៃគូនានា និងសម្រាប់ជាក្របខ័ណ្ឌមួយ ដើម្បីវាស់វែងការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងការផ្តល់សេវា ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព និងការលើកស្ទួយឱ្យមានកំណើន និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព។
- **កម្មវិធីវិនិយោគ០៣ឆ្នាំរំកិលប្រចាំឆ្នាំ** : គឺជាការបង្ហាញពីគម្រោង ដែលបានជ្រើសរើសចេញពីបញ្ជីអាទិភាពផ្អែកតាមផែនការ





អភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ របស់ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីវិនិយោគនឹងបង្ហាញអំពីគម្រោងដែលត្រូវអនុវត្ត តម្លៃវិនិយោគប្រចាំឆ្នាំ និងប្រភពមូលនិធិ។ កម្មវិធីវិនិយោគនេះ ត្រូវធ្វើបច្ចុប្បភាពជារៀងរាល់ឆ្នាំ ក្នុងនោះត្រូវធ្វើការរំកិលមកឆ្នាំបន្ទាប់ទៀត ក្នុងករណីដែលកម្មវិធីវិនិយោគឆ្នាំចាស់មិនទាន់អនុវត្តចប់។

- **គម្រោងថវិកាប្រចាំឆ្នាំ** : គឺជាថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ ថវិកានេះ គឺជាលិខិតគតិយុត្ត ដែលក្រុមប្រឹក្សាមានសិទ្ធិពេញលេញក្នុងការគ្រោងចំណូលចំណាយ និងអនុវត្តចំណូលចំណាយក្នុងរយៈពេល១ឆ្នាំតាមគម្រោងថវិកានេះ។
- **ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** : ជាការធ្វើផែនការចំណា-យសាធារណៈដែលមានរយៈពេលពី ០៣ ដល់ ០៥ឆ្នាំ ដែលកំណត់អំពីតម្រូវការធនធាននាពេលអនាគតសម្រាប់សេវាកម្ម និងការអភិវឌ្ឍដែលស្ថិតក្នុងបរិបទនៃការប៉ាន់ស្មានធនធានសរុបរបស់រដ្ឋ-បាលថ្នាក់ក្រោមជាតិ ដែលបានមកពីប្រភពក្នុងមូលដ្ឋាន និងប្រភពពីខាងក្រៅ។

## ២.២. អំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវចែងអំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដែលមានខ្លឹមសារមួយចំនួនដូចខាងក្រោម :

### ក). ប្រភេទនៃការប្រជុំ

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានពីរប្រភេទគឺ :

- កិច្ចប្រជុំសាមញ្ញ និង
- កិច្ចប្រជុំវិសាមញ្ញ ។

☞ **កិច្ចប្រជុំសាមញ្ញ**

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងហោចណាស់ចំនួនដប់ពីរ(១២) ដងជារៀងរាល់ឆ្នាំ ។
- កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវប្រារព្ធធ្វើឡើងមុនម្ភៃប្រាំ(២៥)ថ្ងៃ និងលើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ ។
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ជាសម័យប្រជុំរបស់ក្រុមប្រឹក្សា ។ រយៈពេលនៃសម័យប្រជុំនីមួយៗរបស់ក្រុមប្រឹក្សា គឺអាស្រ័យលើរបៀបវារៈនៃសម័យប្រជុំរបស់ក្រុមប្រឹក្សា ។ ក្នុងន័យនេះ ក្រុមប្រឹក្សាអាចកំណត់រយៈពេលប្រជុំសាមញ្ញ អាស្រ័យលើរបៀបវារៈនៃកិច្ច





ប្រជុំ ។ ឧទាហរណ៍ : ១ថ្ងៃ ឬ២ថ្ងៃ ឬ៣ថ្ងៃ... ។ល ។

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន សម្រាប់រយៈពេលដប់ពីរ(១២)ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងប្រតិទិនសម្រាប់កិច្ចប្រជុំលើកក្រោយៗទៀតក្នុងរយៈពេលដប់ពីរ(១២)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់ ។
- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវ ប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេលមិនឱ្យលើសពីបី(០៣)ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័ត ។
- គ្រប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ត្រូវមានលិខិតអញ្ជើញដែលត្រូវប្រគល់ជូនសមាជិកគ្រប់រូបនៃក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានាក្នុងរយៈពេលបី(០៣)ថ្ងៃការងារមុនកិច្ចប្រជុំចាប់ផ្តើម ។
- អង្គប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងករណីចាំបាច់ដែលក្រុមប្រឹក្សាត្រូវប្រជុំជាសម្ងាត់ ។ ការប្រជុំជាសម្ងាត់ត្រូវធ្វើឡើងឱ្យបានស្របតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- កាលបរិច្ឆេទ និងទីកន្លែងប្រជុំរបស់ក្រុមប្រឹក្សាត្រូវបិទផ្សាយនៅលើក្តារខៀនព័ត៌មានសាធារណៈរបស់ក្រុមប្រឹក្សា ព្រមទាំងមធ្យោបាយផ្សព្វផ្សាយនានាដែលមាននៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

☞ **កិច្ចប្រជុំវិសាមញ្ញ**

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ។
- ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី(១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល អាចស្នើសុំឱ្យមានកិច្ចប្រជុំវិសាមញ្ញបាន។
- អភិបាល និង/ឬ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចស្នើកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តលើកិច្ចការពិសេស និងបន្ទាន់ណាមួយ ដែលច្បាប់ និងលិខិតបទដ្ឋាននានា តម្រូវឱ្យសុំការសម្រេចពីក្រុមប្រឹក្សា។
- លិខិតអញ្ជើញសម្រាប់កិច្ចប្រជុំវិសាមញ្ញ ត្រូវចែកជូនដល់សមាជិកក្រុមប្រឹក្សាគ្រប់រូប ឱ្យបានយ៉ាងតិចពីរ(០២)ថ្ងៃការងារ មុនកិច្ចប្រជុំចាប់ផ្តើម។

## ខ). ការអញ្ជើញអ្នកចូលរួម

- ប្រធានក្រុមប្រឹក្សាជាអ្នកកោះអញ្ជើញសមាជិករបស់ខ្លួនឱ្យចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- លិខិតអញ្ជើញត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទីកន្លែង កាលបរិច្ឆេទ (ម៉ោង ថ្ងៃ ខែ ឆ្នាំ) និងរបៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ប្រសិនបើមាន។





- គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុញ្ញាតឱ្យសាធារណជនចូលរួមបានទៅតាមចំនួនកន្លែងដែលមាន លើកលែងតែកិច្ចប្រជុំសម្ងាត់។

## គ). ការរៀបចំរបៀបវារៈ

- ប្រធានក្រុមប្រឹក្សា ដោយមានការពិគ្រោះយោបល់ជាមួយអភិបាល និងដោយមានជំនួយពីនាយករដ្ឋបាល ត្រូវរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ សម្រាប់កិច្ចប្រជុំ នីមួយៗរបស់ក្រុមប្រឹក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័ត។
- ប្រធានក្រុមប្រឹក្សា អភិបាល គណៈអភិបាល សមាជិកក្រុមប្រឹក្សាមួយភាគបី(១/៣)នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា អាចស្នើសុំដាក់បញ្ចូលរបៀបវារៈសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបាន។ ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ត្រូវពិគ្រោះយោបល់ ពិភាក្សា និងឱ្យមានការឯកភាពគ្នាក្នុងគណៈកម្មាធិការរបស់ខ្លួនជាមុនសិន មុននឹងដាក់ស្នើរបៀបវារៈណាមួយសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា។

### ឃ). ការរៀបចំទីកន្លែងប្រជុំ

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំទីកន្លែងឱ្យបានសមស្រប ដោយធ្វើការបែងចែកឱ្យបានច្បាស់លាស់អំពីទីកន្លែងសម្រាប់សមាជិកក្រុមប្រឹក្សា គណៈអភិបាល អ្នកពាក់ព័ន្ធ និងសម្រាប់សាធារណជន ។
- ការរៀបចំកន្លែងអង្គុយរបស់ សមាជិកក្រុមប្រឹក្សាម្នាក់ៗត្រូវរៀបតាមលំដាប់អាយុ ដោយផ្តល់អាទិភាពឱ្យអ្នកដែលមានអាយុច្រើនជាងគេអង្គុយខាងមុខ ។

### ង). ប្រធានអង្គប្រជុំ

- ប្រធានក្រុមប្រឹក្សា ត្រូវធ្វើជាប្រធានអង្គប្រជុំ(អធិបតី) ទាំងអស់របស់ក្រុមប្រឹក្សា ។
- ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាត្រូវធ្វើជាប្រធានអង្គប្រជុំ ។
- ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលំដាប់បន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាអវត្តមាន សមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនជាប់ឆ្នោតលំដាប់ទី២ក្នុងក្រុមប្រឹក្សាត្រូវធ្វើជាប្រធានអង្គប្រជុំ ។
- ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនជាប់ឆ្នោតលំដាប់ទី២ក្នុងក្រុមប្រឹក្សាអវត្តមាន សមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះ ត្រូវធ្វើជាប្រធានអង្គប្រជុំ ។





## ២.៣. អំពីរបៀបរបបប្រជុំរបស់ក្រុមប្រឹក្សា

### ក). កូរ៉ុមនៃការប្រជុំ

- រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមានសុពលភាពទៅបានលុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។
- ក្នុងពេលកំពុងដំណើរការកិច្ចប្រជុំ បើប្រធានអង្គប្រជុំពិនិត្យឃើញថា កូរ៉ុមនៃកិច្ចប្រជុំមិនគ្រប់គ្រាន់ ប្រធានអាចផ្អាកការប្រជុំបាន ។ ការប្រជុំបន្តត្រូវធ្វើឡើងនៅថ្ងៃធ្វើការងារបន្ទាប់រហូតដល់អស់របៀបវារៈនៃកិច្ចប្រជុំដែលបានអនុម័តរួចហើយ ។
- ក្នុងករណីមានបញ្ហាអ្វីដែលត្រូវលើកឡើង ឬជម្រាបជូនអង្គប្រជុំ ប្រធានអង្គប្រជុំអាចថ្លែងសេចក្តីនោះមុននឹង ចាប់ផ្តើមប្រជុំតាមរបៀបវារៈ ។

## ខ). ដំណើរការនៃកិច្ចប្រជុំ

☞ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដំណើរការកិច្ចប្រជុំរបស់ខ្លួនតាមនីតិវិធីដូចខាងក្រោម :

- ពិនិត្យកូរ៉ុមសម្រាប់កិច្ចប្រជុំ
- ពិនិត្យ និងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ ដែលមានជាអាទិ៍ :
  - ពិនិត្យ និងអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកមុន
  - ពិនិត្យ ពិភាក្សា និងអនុម័តលើប្រធានបទនីមួយៗ ដែលមាននៅក្នុងរបៀបវារៈ
  - ពិនិត្យ ពិភាក្សា និងអនុម័តលើបញ្ហាផ្សេងៗ ។
- ប្រកាសជូនព័ត៌មានអំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់នៃកិច្ចប្រជុំលើកក្រោយ ។

☞ សមាជិកម្នាក់ៗនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានបំណងបញ្ចេញមតិយោបល់ត្រូវលើកដៃសុំការអនុញ្ញាតពីប្រធានអង្គប្រជុំ ។

☞ រយៈពេលបញ្ចេញមតិរបស់សមាជិកម្នាក់ៗ ក្នុងមួយលើកៗមិនលើសពី ១៥នាទី ហើយត្រូវមានមតិតែពីបញ្ហាដែលកំពុងពិភាក្សា ។ ប្រធានអង្គប្រជុំអាចអនុញ្ញាតបន្ថែមពេល៥នាទីទៀតបាន ប្រសិនបើយល់ឃើញថាជាការមានប្រយោជន៍ដល់បញ្ហាដែលកំពុងពិភាក្សា ។ ការបន្ថែមនេះអាចអនុញ្ញាតឱ្យបន្តបាន ២ដង ក្នុងបញ្ហាដដែល ។





☞ ក្នុងករណីសមាជិកក្រុមប្រឹក្សារូបណាមានមតិក្រៅពីប្រធានបទ ប្រធានអង្គប្រជុំត្រូវរំលឹកឱ្យមានមតិតែពីបញ្ហាដែលកំពុងពិភាក្សា ។ ក្នុងករណីដែលប្រធានក្រើនរំលឹកហើយ សមាជិកនោះនៅតែពុំព្រមអនុវត្តតាមប្រធានអង្គ ប្រជុំមានសិទ្ធិបញ្ឈប់ការមានមតិរបស់សមាជិកនោះ ។ ករណីកាន់តែធ្ងន់ធ្ងរជាងនេះ ប្រធានអង្គប្រជុំត្រូវបណ្តេញសមាជិករូបនោះចេញពីអង្គប្រជុំសម្រាប់របៀបវារៈ ដែលកំពុងតែពិភាក្សានោះ ។ ចំពោះរបៀបវារៈផ្សេងពីនេះ សមាជិកដែលត្រូវបណ្តេញចេញនោះមានសិទ្ធិចូលរួមប្រជុំជាធម្មតាវិញបាន ។

☞ រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ត្រូវអនុញ្ញាតឱ្យតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារយ៉ាងច្រើនពីរ(០២)រូប និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាដើម្បីចូលរួម លើកលែងតែកិច្ចប្រជុំសម្ងាត់ ។

## គ). វិធានការទប់ស្កាត់ការរំខានក្នុងពេលប្រជុំ

☞ ប្រធានអង្គប្រជុំត្រូវក្រើនរំលឹកចំពោះសមាជិកក្រុមប្រឹក្សាណា ដែលមានមតិក្រៅពីប្រធានបទដែលកំពុងពិភាក្សា ឬមានមតិលើសពីរយៈពេលដែលអនុញ្ញាតដោយប្រធានអង្គប្រជុំ ។

☞ ក្នុងករណីទទួលការក្រើនរំលឹកចំនួនមួយ(០១)ដងហើយ សមាជិករូបនោះនៅតែប្រព្រឹត្តខុសឆ្គងថែមទៀត ប្រធានអង្គប្រជុំត្រូវក្រើនរំលឹកម្តងទៀត និងត្រូវចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំអំពីការក្រើនរំលឹក

នោះ។ ករណីសមាជិករូបនោះនៅតែប្រព្រឹត្តខុសឆ្គងម្តងទៀត ប្រធានអង្គប្រជុំត្រូវបញ្ឈប់ការមានមតិរបស់សមាជិករូបនោះ។ ករណីបញ្ឈប់មិនឱ្យមានមតិ តែសមាជិករូបនោះនៅតែចចេសរឹងរូស ប្រធានអង្គប្រជុំត្រូវចាត់វិធានការបណ្តេញសមាជិកនោះចេញពីអង្គប្រជុំក្រុមប្រឹក្សា។

☞ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា បើមានសមាជិកណាបង្កភាពច្របូកច្របល់ ឬនាំអាទឹដល់សមាជិកក្រុមប្រឹក្សាផ្សេងទៀតឱ្យបង្កភាពច្របូកច្របល់ក្នុងកិច្ចប្រជុំ ឬជេរប្រមាថមើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែងសមាជិកក្រុមប្រឹក្សាដទៃទៀតក្នុងកិច្ចប្រជុំ ប្រធានអង្គប្រជុំត្រូវចាត់វិធានការឱ្យសមាជិករូបនោះ គោរពបទបញ្ជាផ្ទៃក្នុង និងរក្សារបៀបរៀបរយនៃកិច្ចប្រជុំ។ ក្នុងករណីដែលសមាជិកនោះ នៅតែចចេសរឹងរូសមិនព្រមគោរពតាមបទបញ្ជាផ្ទៃក្នុង ប្រធានអង្គប្រជុំត្រូវចាត់វិធានការដោយចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ និងត្រូវបណ្តេញសមាជិកនោះចេញពីអង្គប្រជុំ ។

☞ ប្រធានអង្គប្រជុំអាចប្រកាសលើកពេលប្រជុំបាន ប្រសិនបើអង្គប្រជុំមានកើតឡើងនូវភាពច្របូកច្របល់ ចលាចល ដែលមិនអាចឱ្យអង្គប្រជុំដំណើរការទៅបាន។

☞ ប្រធានអង្គប្រជុំត្រូវរក្សាការពារ កុំឱ្យមានភាពច្របូកច្របល់នៅខាងក្នុង និងខាងក្រៅកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។ ដើម្បីធ្វើឱ្យសម្រេចកិច្ចការនេះ ប្រធានអង្គប្រជុំអាចប្រើប្រាស់កំលាំងនគរបាល ឬកងរាជអាវុធហត្ថនៅក្នុងមូលដ្ឋានរបស់ខ្លួនតាមការជាក់ស្តែង។





## ឃ). អំពីកំណត់ហេតុនៃកិច្ចប្រជុំ

☞ កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវកត់ត្រានូវបញ្ហាដូចខាងក្រោម :

- ទីកន្លែង និងកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ និងម៉ោង) នៃកិច្ចប្រជុំ។
- ការបញ្ជាក់អះអាងថា ការប្រជុំមានលក្ខណៈស្របច្បាប់ (កូរ៉ុម របៀបវារៈ ការបន្ថែមរបៀបវារៈ...) ។
- បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ដែលមានវត្តមាន និងអវត្តមាន។
- បញ្ជីឈ្មោះ និងអង្គភាពរបស់អ្នកដែលចូលរួមប្រជុំ (ប្រសិនបើមាន)
- ចំនួនសាធារណជនដែលបានអញ្ជើញចូលរួម (ប្រសិនបើមាន) ។
- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាផ្សេងៗក្នុងរបៀបវារៈនៃកិច្ចប្រជុំ រួមទាំងបញ្ហាដែលបានបន្ថែមនៅក្នុងរបៀបវារៈ។
- របៀបវារៈ ពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំលើកក្រោយ។
- បញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា។
- ពេលវេលាបិទអង្គប្រជុំ។

☞ កំណត់ហេតុនៃកិច្ចប្រជុំត្រូវកត់ត្រានូវពាក្យពេចន៍ និងឃ្លាប្រយោគសំខាន់ៗនៃកិច្ចពិភាក្សា ដោយមិនត្រូវកត់ត្រាសង្ខេបខ្លាំងពេកនាំឱ្យបាត់បង់នូវខ្លឹមសារនៃកិច្ចប្រជុំឡើយ។

☞ សេចក្តីព្រាងកំណត់ហេតុ ត្រូវតែចែកជូនដល់សមាជិកក្រុមប្រឹក្សាគ្រប់រូបយ៉ាងតិចចំនួនប្រាំ(០៥)ថ្ងៃមុនកិច្ចប្រជុំបន្ទាប់។

☞ សេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាត្រូវដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញបន្ទាប់ដើម្បីអនុម័ត។

## ២.៤. អំពីដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា

### ក) ការអនុម័ត

☞ រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើដីកា ឬសេចក្តីសម្រេចនានាតាមការចាំបាច់ទាក់ទិននឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សា រួមគ្នាក្រុមប្រឹក្សាប្រភេទផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា





- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

☞ សេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចយកជាការបាន លុះត្រាតែសេចក្តីសម្រេច ឬដីកានោះត្រូវបានអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព។

☞ សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របជាមួយបទបញ្ជាផ្ទៃក្នុងនេះនឹងពុំមានសុពលភាពឡើយ។

☞ សេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សាទាំងឡាយណាដែលខុសច្បាប់ សេចក្តីសម្រេចឬដីកានោះពុំមានសុពលភាពឡើយ។

- ☞ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងករណីបោះឆ្នោតអនុម័តលើការបញ្ឈប់ពីតំណែងចំពោះសមាជិកក្រុមប្រឹក្សាណាម្នាក់ ដែលមិនគោរពបទបញ្ជាផ្ទៃក្នុងក្រុមសីលធម៌របស់ក្រុមប្រឹក្សា និងការស្នើសុំដកហូតអភិបាល អភិបាលរងណាម្នាក់ចេញពីមុខតំណែង ត្រូវធ្វើតាមវិធីបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។
- ☞ លទ្ធផលនៃការបោះឆ្នោតអនុម័ត ត្រូវប្រកាសភ្លាមៗនូវចំនួនសម្លេងយល់ព្រម សម្លេងជំទាស់ និងសម្លេងអនុប្បវាទ ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ។
- ☞ ប្រធានអង្គប្រជុំត្រូវចាត់ឱ្យធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្ដីសម្រេច ឬដីកាដែលត្រូវបានក្រុមប្រឹក្សាអនុម័ត។
- ☞ សេចក្ដីសម្រេច ឬដីការបស់ក្រុមប្រឹក្សាត្រូវបិទផ្សាយនៅលើក្ដារខៀនព័ត៌មានសាធារណៈរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ដែលមាននៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងយឺតបំផុតរយៈពេលប្រាំ(០៥)ថ្ងៃការងារ បន្ទាប់ពីថ្ងៃអនុម័ត។





### ខ) ការកែប្រែដីកា ឬសេចក្ដីសម្រេច

- សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី (១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលអាចស្នើសុំធ្វើការកែប្រែ សេចក្ដីសម្រេច ឬដីការបស់ក្រុមប្រឹក្សា។
- សំណើសុំកែប្រែនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការស្នើសុំកែប្រែនេះ។ សមាជិកដែលស្នើសុំ ត្រូវដាក់ជូនសំណើនេះនៅក្នុងអំឡុងនៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ឬអាចដាក់ជូនទៅនាយករដ្ឋបាល ដើម្បីរាយការណ៍ជូនប្រធានក្រុមប្រឹក្សា។
- ក្រុមប្រឹក្សាត្រូវចាត់ឱ្យធ្វើការសិក្សាអំពីសំណើនេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញបន្ទាប់ ឬកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់។

## ២.៥. អំពីសិទ្ធិអំណាចរបស់ប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា

### ក). ប្រធានក្រុមប្រឹក្សា

ប្រធានក្រុមប្រឹក្សាមាន តួនាទី ភារកិច្ច និងសិទ្ធិអំណាចដូចខាងក្រោម :

- ត្រៀមរៀបចំសេចក្ដីព្រាងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន

- ធានាឱ្យគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រព្រឹត្តទៅក្នុងលក្ខណៈ ប្រជាធិបតេយ្យ មិនលំអៀង មានរបៀបរៀបរយ និងគ្មានការរំខាន
- បង្កលក្ខណៈឱ្យសមាជិកក្រុមប្រឹក្សាអាចបញ្ចេញមតិ យោបល់
- តំណាងឱ្យក្រុមប្រឹក្សា ក្នុងការចាត់ចែង និងទំនាក់ទំនងការងារនានានៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រុមប្រឹក្សារបស់ខ្លួន
- ប្រធានក្រុមប្រឹក្សាអាចអញ្ជើញអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធាន ឬតំណាងមន្ទីរ អង្គភាព ឬអ្នកពាក់ព័ន្ធនានាឱ្យចូលរួមក្នុងកិច្ចប្រជុំណាមួយក៏បាន តាមការចាំបាច់។ អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធាន ឬតំណាងមន្ទីរ អង្គភាព ឬអ្នកពាក់ព័ន្ធនានា ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំ មានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោត អនុម័តបានឡើយ
- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬអភិបាល និងបុគ្គលិកក្រុមប្រឹក្សា ដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ប្រធានអង្គប្រជុំមានសិទ្ធិបណ្តេញសមាជិកក្រុមប្រឹក្សា គណៈអភិបាល អ្នកពាក់ព័ន្ធ និង/ឬសាធារណជនចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលជននោះមិនគោរពតាមបទបញ្ជាផ្ទៃក្នុង ហើយចចេស





រឹងរូសធ្វើឱ្យខូចរបៀបរៀបរយនៃអង្គប្រជុំរបស់ក្រុមប្រឹក្សា បន្ទាប់ពីប្រធានអង្គប្រជុំបានដាស់តឿនជាញឹកញាប់ ដើម្បីស្នើសុំឱ្យរក្សារបៀបរៀបរយក្នុងកិច្ចប្រជុំ។

## ២). សមាជិកក្រុមប្រឹក្សា

សមាជិកក្រុមប្រឹក្សាមានតួនាទី និងសិទ្ធិអំណាចដូចខាងក្រោម :

- សមាជិកក្រុមប្រឹក្សា មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន
- គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ឬប្រឈមនឹងសកម្មភាព ឬចំណាត់ការណាមួយ ដោយសារតែហេតុផលនៃការបញ្ចេញមតិ ឬការបោះឆ្នោតរបស់ខ្លួនក្នុងអង្គប្រជុំក្រុមប្រឹក្សាឡើយ
- សមាជិកក្រុមប្រឹក្សាគ្រប់រូបមិនអាចបញ្ចេញមតិយោបល់ក្នុងនាមក្រុមប្រឹក្សាទាំងមូលបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្ទាប់ពីកិច្ចប្រជុំ
- គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាអាចចោទសួរទៅអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីស្ថានភាពនៃការអនុវត្តសេចក្តីសម្រេច ឬដីការបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល

- សមាជិកក្រុមប្រឹក្សាគ្រប់រូបត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវ :
  - វិន័យ
  - ការណែនាំ និងការចាត់ចែងរបស់ប្រធានអង្គប្រជុំ
  - បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- សមាជិកក្រុមប្រឹក្សាទាំងអស់ត្រូវទទួលខុសត្រូវអំពីកិច្ចការ និងអំពើរបស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ និងកិត្តិយសរបស់ក្រុមប្រឹក្សា។

## ២.៦. អំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

☞ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវតែបង្កើតគណៈកម្មាធិការចំនួនបី ដែលកំណត់ដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានដូចខាងក្រោម :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម

☞ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងបី(០៣)ខាងលើនេះ ត្រូវផ្អែកតាមអនុក្រឹត្យ ប្រកាសក្រសួងមហាផ្ទៃ និងប្រកាសអន្តរក្រសួង។ ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងទៀត ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់។





☞ ដើម្បីពិភាក្សាលើបញ្ហាណាមួយ ដែលអាចដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាអាចចាត់ឱ្យគណៈកម្មាធិការណាមួយដែលមានភារកិច្ចពាក់ព័ន្ធនឹងបញ្ហានោះ ធ្វើការសិក្សាស្រាវជ្រាវ និងលើកយោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន។ ក្រុមប្រឹក្សាក៏អាចចាត់ឱ្យគណៈកម្មាធិការច្រើនជាងមួយ ដើម្បីសហការគ្នាធ្វើការសិក្សាស្រាវជ្រាវ លើកយោបល់លើបញ្ហាដែលពាក់ព័ន្ធគ្នា ជូនក្រុមប្រឹក្សាពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

☞ គណៈអភិបាល និងនាយករដ្ឋបាល ត្រូវផ្ដល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងលេខាធិការដ្ឋាន ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការក្នុងអំឡុងពេល ដែលគណៈកម្មាធិការធ្វើការសិក្សាស្រាវជ្រាវខាងលើនេះ។

## ២.៧. អំពីតួនាទី ភារកិច្ច និងសិទ្ធិរបស់គណៈអភិបាល និងនាយករដ្ឋបាល

### ក). តួនាទី ភារកិច្ច និងសិទ្ធិរបស់គណៈអភិបាល

អភិបាល និង ឬគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាច :

- ស្នើសុំទៅប្រធានក្រុមប្រឹក្សា ដើម្បីដាក់បញ្ចូលរបៀបវារៈណាមួយទៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ស្នើកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ដើម្បីពិនិត្យ ពិភាក្សា និង

អនុម័តលើកិច្ចការពិសេស និងបន្ទាន់ណាមួយដែលច្បាប់ និងលិខិតបទដ្ឋាននានាតម្រូវឱ្យសុំការសម្រេចពីក្រុមប្រឹក្សា។

- គណៈអភិបាលត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពី លទ្ធផលនៃការអនុវត្តសេចក្ដីសម្រេច ឬដីការបស់ក្រុមប្រឹក្សា ព្រមទាំងសកម្មភាព ដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយ ទៅអង្គប្រជុំសាមញ្ញមួយ។

## ខ). នាយករដ្ឋបាល

នាយករដ្ឋបាលត្រូវ :

- ធ្វើជាជំនួយការឱ្យក្រុមប្រឹក្សាក្នុងការរៀបចំរបៀបវារៈនៃកិច្ចប្រជុំ ឯកសារពាក់ព័ន្ធនានា លិខិតអញ្ជើញ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ត្រូវទទួលបន្ទុកថតចម្លងកំណត់ហេតុ ដែលបានអនុម័តរួច ចែកជូនគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ បញ្ជូនមកក្រសួងមហាផ្ទៃ និងរក្សាទុកជាឯកសារ។
- ទទួលភារកិច្ចក្នុងការថតចម្លងបទបញ្ជាផ្ទៃក្នុង ឬខ្លឹមសារនៃការកែប្រែបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ផ្ញើជូនគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ ក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធ ។
- ថែរក្សាឱ្យបានគង់វង្សនូវឯកសារចម្លងនៃរបៀបវារៈកិច្ចប្រជុំ





ឯកសារ កំណត់ហេតុ និងមាតិកាសំខាន់ៗនៃកិច្ចប្រជុំ ដើម្បីឱ្យសាធារណជនអាចពិនិត្យមើល ឬចម្លងចែកជូនសាធារណជនដែលមានបំណងស្នើសុំ ដោយត្រូវបង់ថ្លៃត្រឹមថ្លៃនៃការថតចម្លងឯកសារប៉ុណ្ណោះ។

- ត្រូវស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាដែលវត្តមាន សមាជិកក្រុមប្រឹក្សា ដែលអវត្តមាន ដោយបញ្ជាក់អំពីមូលហេតុអវត្តមាននោះឱ្យបានច្បាស់លាស់។

## ២.៨. អំពីការខកខានមិនបានចូលរួមប្រជុំ

- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ្រប់រូបត្រូវតែចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកក្រុមប្រឹក្សាត្រូវដាក់ពាក្យសុំអនុញ្ញាតជាលាយលក្ខណ៍អក្សរជូនប្រធានក្រុមប្រឹក្សាយ៉ាងតិចមួយ(០១)ថ្ងៃមុនកិច្ចប្រជុំ។
- ប្រធានក្រុមប្រឹក្សា អាចអនុញ្ញាតច្បាប់ឱ្យសមាជិកក្រុមប្រឹក្សាអវត្តមានក្នុងកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាបានតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីស្នើសុំឈប់សម្រាកពីរ(០២)លើកជាប់ៗគ្នា ត្រូវសុំឱ្យក្រុមប្រឹក្សាអនុម័ត។
- ក្នុងករណីសមាជិកក្រុមប្រឹក្សាណាម្នាក់ដើរចេញពីអង្គប្រជុំត្រូវចាត់ទុកជាអវត្តមានដោយគ្មានច្បាប់មួយដង។

- សមាជិកក្រុមប្រឹក្សា ដែលអវត្តមានក្នុងកិច្ចប្រជុំសាមញ្ញចំនួនពីរ (០២) លើកជាប់ៗគ្នាដោយមានជំងឺ ត្រូវមានឯកសារបញ្ជាក់ពីគ្រូពេទ្យ ។
- សមាជិកក្រុមប្រឹក្សាណាម្នាក់ ក្រោយពីទទួលបានលិខិតអញ្ជើញហើយ តែមិនបានចូលរួមប្រជុំដោយគ្មានការអនុញ្ញាត សមាជិកក្រុមប្រឹក្សារូបនោះត្រូវទទួលទណ្ឌកម្មខាងវិន័យ ។ ទណ្ឌកម្មអាចមានដូចជា :
    - ប្រសិនបើខកខានមិនបានមកប្រជុំ ដោយគ្មានច្បាប់អនុញ្ញាតចំនួនមួយ(០១) លើក ត្រូវទទួលការក្រើនរំលឹក ពីប្រធានក្រុមប្រឹក្សា និងត្រូវចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំនោះ ។
    - ប្រសិនបើខកខានមិនបានមកប្រជុំ ដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរលើកមិនជាប់គ្នាក្នុងអំឡុងពេល១២ខែ ត្រូវទទួលការក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ និងត្រូវកាត់ប្រាក់បំណាច់ចំនួនម្ភៃប្រាំ(២៥) ភាគរយនៃខែអវត្តមានលើកទី២ ។
    - ប្រសិនបើខកខានមិនបានមកប្រជុំ ដោយគ្មានច្បាប់អនុញ្ញាតចំនួនបី(០៣) លើកមិនជាប់គ្នាក្នុងអំឡុងពេល១២ខែត្រូវទទួលការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ និងត្រូវកាត់ប្រាក់ឧបត្ថម្ភចំនួនហាសិប(៥០) ភាគរយនៃខែអវត្តមានលើកទី៣ ។
    - ក្នុងករណីអនុវត្តទណ្ឌកម្មខាងវិន័យខាងលើនេះរួចហើយ សាមី





ខ្លួនមិនព្រមរាងចាល ក្រុមប្រឹក្សាត្រូវដាក់ករណីនេះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ដើម្បីអនុម័តបណ្តេញសមាជិកនោះចេញពីក្រុមប្រឹក្សារបស់ខ្លួន ។
    - ប្រសិនបើខកខានមិនបានមកប្រជុំសាមញ្ញ ដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរ(០២) លើកជាប់ៗគ្នា ត្រូវបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ។
- ប្រធានក្រុមប្រឹក្សា ត្រូវចាត់ចែងធ្វើជាលាយលក្ខណ៍អក្សរនូវរាល់ការក្រើនរំលឹក ការស្តីបន្ទោស ការដាក់វិន័យ និងការបញ្ឈប់ពីសមាជិកក្រុមប្រឹក្សាឱ្យដល់លំនៅដ្ឋាននៃសមាជិកក្រុមប្រឹក្សា ដែលទទួលទណ្ឌកម្មខាងវិន័យនោះ ។

**បញ្ជាក់ :** ប្រាក់ដែលបានមកពីការពិន័យ ត្រូវដាក់បញ្ចូលជាថវិការបស់ក្រុមប្រឹក្សា ។

## ២.៩. ការកែប្រែបទបញ្ជាផ្ទៃក្នុង

- សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបីនៃសមាជិកក្រុមប្រឹក្សាទាំងអស់មានសិទ្ធិស្នើសុំដើម្បីកែប្រែបទបញ្ជាផ្ទៃក្នុងនេះបាន ។
- សំណើសុំកែប្រែបទបញ្ជាផ្ទៃក្នុង ត្រូវអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ហើយត្រូវលើកយកមកពិភាក្សាសម្រេច នៅក្នុងកិច្ចប្រជុំសាមញ្ញបន្ទាប់របស់ក្រុមប្រឹក្សា ។

# ផ្នែកទី ៤
# ការរៀបចំផែនការសកម្មភាពការងារ
# របស់ក្រុមប្រឹក្សា





## ផ្នែកទី ៤
## ការរៀបចំផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សា

### ១. ទស្សនទាននៃការរៀបចំផែនការសកម្មភាពការងារ

### ១.១. និយមន័យ

ផែនការសកម្មភាព គឺជាការគ្រោងគិតអំពីសកម្មភាពការងារ ពេលវេលា អ្នកទទួលខុសត្រូវ និងការប៉ាន់ប្រមាណអំពីលទ្ធភាពខាងធនធាន ដែលត្រូវអនុវត្តតួនាទី មុខងាររបស់រដ្ឋបាលនីមួយៗ ឬរបស់អង្គភាពនីមួយៗសម្រាប់រយៈពេលមួយជាកំណត់។ ឧទាហរណ៍ : រយៈពេលមួយឆ្នាំ មួយឆមាស ។ល។ ការកសាងផែនការសកម្មភាពមិនគ្រាន់តែពិនិត្យមើលសកម្មភាពការងារនានា ដែលកំពុងមាននាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតប្រមើលមើលអំពីសកម្មភាពការងារ សំដៅសម្រេចបាននូវទស្សនវិស័យ គោលដៅ យុទ្ធសាស្ត្រដែលថ្នាក់រដ្ឋបាលនីមួយៗបានកំណត់ផងដែរ។

### ១.២. សារសំខាន់នៃការកសាងផែនការសកម្មភាពការងារ

ការកសាងផែនការសកម្មភាពការងារល្អ នឹងផ្តល់នូវការតម្រង់ទិសមួយយ៉ាងត្រឹមត្រូវសម្រាប់តម្រង់ទិសការងារឱ្យប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ ទាន់ពេលវេលា ហើយភាពរីកចម្រើននៃការអនុវត្តសកម្មភាពនោះ នឹងចូលរួមសម្រេចនូវតួនាទី មុខងារ និងការទទួលខុសត្រូវរបស់ថ្នាក់រដ្ឋបាលមួយ ឬស្ថាប័នមួយ ឬអង្គភាពមួយ។ ផែនការសកម្មភាពការងារមានលក្ខណៈមិន

ដូចគ្នាទាំងស្រុងទៅនឹងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឡើយ។ សកម្មភាពនានាដើម្បីអនុវត្តសម្រេចនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគត្រូវតែដាក់បញ្ចូលក្នុងផែនការសកម្មភាពការងារពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត។

## ១.៣. សមាសភាពសំខាន់ៗនៃផែនការសកម្មភាព

ដើម្បីរៀបចំកសាងផែនការសកម្មភាពការងារឱ្យបានល្អ គ្រប់ជ្រុងជ្រោយ ក្រុមប្រឹក្សាត្រូវចាត់ឱ្យអ្នកធ្វើផែនការសកម្មភាពនោះពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- **កិច្ចការ ឬសកម្មភាព** : គឺជាកិច្ចការ ឬសកម្មភាពនានា ដែលត្រូវអនុវត្តក្នុងរយៈពេលកំណត់។ ប្រសិនបើផែនការសកម្មភាពប្រចាំខែ កិច្ចការ ឬសកម្មភាពត្រូវតែជាកិច្ចការ ឬសកម្មភាពដែលត្រូវអនុវត្តក្នុងរយៈពេល១ខែ។ ដូចគ្នាដែរ ប្រសិនបើផែនការសកម្មភាពរយៈពេលបីខែ កិច្ចការ ឬសកម្មភាពត្រូវតែជាកិច្ចការ ឬសកម្មភាពដែលត្រូវអនុវត្តក្នុងរយៈពេលបីខែនោះ។
  ឧទាហរណ៍ : សកម្មភាពប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា។
- **គោលបំណង** : គឺជាគោលបំណងនៃការអនុវត្តសកម្មភាព។ ឧទាហរណ៍ : គោលបំណងនៃការប្រជុំប្រចាំខែ គឺដើម្បីពិនិត្យមើលភាពរីកចម្រើននៃការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា។





- **ធនធាន** : គឺជាឧបករណ៍ មធ្យោបាយ សម្ភារៈ ថវិកា ដែលត្រូវប្រើក្នុងការអនុវត្តសកម្មភាព។ ឧទាហរណ៍ : បន្ទប់ប្រជុំ ក្រដាសផ្ទាំងធំ ថវិកាសម្រាប់ប្រតិបត្តិការ និងសម្រាប់ប្រជុំអំពីរបាយការណ៍ តាមដានត្រួតពិនិត្យ...។
- **ពេលវេលា** : គឺជាពេលវេលាជាក់លាក់សម្រាប់អនុវត្តសកម្មភាព។ ឧទាហរណ៍ : ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឬ អាចកំណត់តាមសប្តាហ៍ ដូចជា សប្តាហ៍ទី២ ខែកញ្ញា ជាដើម។
- **លទ្ធផលរំពឹងទុក** : គឺជាលទ្ធផលដែលសង្ឃឹមថាទទួលបានពីការអនុវត្តសកម្មភាពនីមួយៗ។
- **អ្នកទទួលខុសត្រូវ** : គឺជាអ្នកដែលទទួលខុសត្រូវជាក់លាក់ ឬអង្គភាពជាក់លាក់ដែលទទួលអនុវត្ត និងដឹកនាំសម្របសម្រួលការអនុវត្តសកម្មភាពនីមួយៗ។

## ២. ផែនការសកម្មភាពការងាររយៈពេលបីខែរបស់ក្រុមប្រឹក្សា

ការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលរួមមានក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ខ្លួន បន្ទាប់ពីប្រកាសចូលកាន់តំណែង ហើយត្រូវពិនិត្យ អនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ របស់ក្រុមប្រឹក្សា។ ក្រោយការអនុម័ត ក្រុមប្រឹក្សា និងគណៈអភិបាល ត្រូវចាត់វិធានការ

សមស្រប ដើម្បីធានាឱ្យផែនការសកម្មភាពរយៈពេល៣ខែនេះ ត្រូវបានអនុវត្តតាមយ៉ាងត្រឹមត្រូវ ដោយអ្នកពាក់ព័ន្ធនានា ។

## ២.១. គោលបំណង

គោលបំណងនៃការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ គឺដើម្បីឱ្យក្រុមប្រឹក្សា គណៈអភិបាលដែលទើបចូលកាន់មុខតំណែងអាចចាប់ផ្ដើមអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានល្អ និងចៀសវាងនូវការខ្វះចន្លោះក្នុងការអនុវត្តសកម្មភាពមួយចំនួនដែលចាំបាច់ ។

ផែនការសកម្មភាពការងារនេះ គឺជាមធ្យោបាយដ៏សំខាន់មួយ ដែលនាំឱ្យមានការផ្លាស់ប្ដូរប្រព័ន្ធការងារ និងប្រព័ន្ធគណនេយ្យភាព ពោលគឺ ក្រុមប្រឹក្សាជាអ្នកទទួលខុសត្រូវអំពីផែនការសកម្មភាពនោះ ហើយគណៈអភិបាលជាអ្នកអនុវត្តផែនការសកម្មភាពនោះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យ ផ្ដល់ការណែនាំតម្រង់ទិសការអនុវត្តសកម្មភាពនានាតាមផែនការសកម្មភាពនោះ ដោយយោងតាមច្បាប់ និងលិខិតបទដ្ឋាននានា ។

តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលបីខែ អាចជួយឱ្យក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ដឹងថា :

- តើសកម្មភាពណាត្រូវអនុវត្តមុន ហើយសកម្មភាពណាត្រូវអនុវត្តបន្ទាប់?
- តើសកម្មភាពនីមួយៗត្រូវអនុវត្តនៅពេលណា?





- តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត?
- តើអ្វីជាលទ្ធផលរំពឹងទុកពីការអនុវត្តសកម្មភាពនីមួយៗនោះ?
- តើមានមធ្យោបាយអ្វីសម្រាប់ផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្ត?
- ...។ល។

## ២.២. អ្នកពាក់ព័ន្ធ និងតួនាទី

អ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមមាន :

- **ក្រុមប្រឹក្សា** : ពិនិត្យ និងអនុម័តសេចក្ដីព្រាងផែនការសកម្មភាពរយៈពេលបីខែរបស់ខ្លួន ត្រួតពិនិត្យ និងតម្រង់ទិសការអនុវត្ត រួមទាំងការផ្ដល់វិធីសាស្ត្រសម្រាប់អនុវត្ត ដោយឈរលើគោលការណ៍អភិបាលកិច្ចល្អនៅរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬបើចាំបាច់ត្រូវកោះប្រជុំវិសាមញ្ញដើម្បីផ្ដល់ការដឹកនាំ ណែនាំ ។
- **គណៈអភិបាល** : មានតួនាទីរៀបចំសេចក្ដីព្រាងផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា សម្រាប់ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សា និងទទួលអនុវត្តផែនការសកម្មភាពនោះ តាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ។
- **អង្គភាពពាក់ព័ន្ធ** : ជួយគណៈអភិបាលក្នុងការរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា

## ២.៣. ដំណើការរៀបចំផែនការសកម្មភាពរយៈពេលបីខែ របស់ក្រុមប្រឹក្សា

### ២.៣.១. អំពីការរៀបចំ

ដោយសារក្រុមប្រឹក្សា ដែលកើតចេញពីការបោះឆ្នោតអាណត្តិទី១នេះ អាចនឹងចាប់ផ្តើមបំពេញការងារចាប់ពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០០៩ តទៅ ហេតុនេះទើបតម្រូវឱ្យរៀបចំផែនការសកម្មភាពបីខែម្តងៗ។ ប៉ុន្តែ ចាប់ពីឆ្នាំ២០១០ទៅ ក្រុមប្រឹក្សាគួររៀបចំផែនការសកម្មភាពការងារមួយឆ្នាំម្តង ដោយបែងចែកជាត្រីមាស និងប្រចាំខែនីមួយៗ។

ចំពោះមុខ ក្រោយកិច្ចប្រជុំសាមញ្ញលើកទី១ ក្រុមប្រឹក្សាត្រូវចាត់វិធានការឱ្យរៀបចំផែនការសកម្មភាពការងាររយៈពេលបីខែដំបូង គឺខែកក្កដា សីហា និងខែកញ្ញា ហើយនៅអំឡុងដើមខែកញ្ញា ក្រុមប្រឹក្សាត្រូវចាត់វិធានការរៀបចំផែនការសកម្មភាពបីខែបន្ទាប់ទៀត គឺសម្រាប់ខែតុលា វិច្ឆិកា និងខែធ្នូ។

ដើម្បីរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សាឱ្យបានគ្រប់ជ្រុងជ្រោយ ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវគិតពិចារណាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការកំណត់ប្រភេទកិច្ចការ
- ការស្រង់បញ្ជីកិច្ចការសំខាន់ៗ
- ការកំណត់ពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ
- ការកំណត់លទ្ធផលរំពឹងទុក
- ការកំណត់អ្នកទទួលខុសត្រូវ





☞ **ការកំណត់ប្រភេទកិច្ចការ** : ដើម្បីងាយស្រួលក្នុងការស្រង់កិច្ចសំខាន់ៗដែលត្រូវអនុវត្ត ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវគិតពិចារណាអំពីប្រភេទកិច្ចការជាមុនសិន។ កិច្ចការទាំងនោះ គួរចែកចេញជា បីប្រភេទ ដូចខាងក្រោម :

- ប្រភេទកិច្ចការទី១ : ជាកិច្ចការដែលបានទទួលខុសត្រូវបន្តពីរដ្ឋបាលមុនការបោះឆ្នោត។
- ប្រភេទកិច្ចការទី២ : កិច្ចការចាំបាច់នានាដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រភេទកិច្ចការទី៣ : កិច្ចការផ្សេងៗតាមលទ្ធភាពជាក់ស្តែងរបស់ក្រុមប្រឹក្សានីមួយៗ។

☞ **ការស្រង់កិច្ចការសំខាន់ៗ** បន្ទាប់ពីកំណត់ប្រភេទកិច្ចការរួច ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវគិតពិចារណាអំពីកិច្ចការ ឬសកម្មភាពនានាទៅតាមប្រភេទនៃកិច្ចការម្តងមួយប្រភេទៗ ដោយកំណត់យកកិច្ចការសំខាន់ៗណា ដែលត្រូវអនុវត្តក្នុងរយៈពេលបីខែដំបូង បន្ទាប់ពីការប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។ ក្នុងប្រភេទកិច្ចការនីមួយៗ ត្រូវរៀបចំតាមវិស័យ/ផ្នែកនានា។ ឧទាហរណ៍ : វិស័យសន្តិសុខសណ្តាប់ធ្នាប់ សង្គម វិស័យសាធារណៈការ វិស័យអប់រំជាដើម។ វិស័យ/ផ្នែកនីមួយៗត្រូវស្រង់ចូលកូឡោនទី១នៃទម្រង់គំរូ "ក"។ កិច្ចការដែលត្រូវស្រង់ទាំងនោះមានដូចជា :

- **ប្រភេទកិច្ចការទី១** រួមមានកិច្ចការមួយចំនួន ដូចជា :

- ការតាមដានការអនុវត្តដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀងនានា
- ការអនុវត្តផែនការ កម្មវិធី គម្រោងនានា ដែលកំពុងអនុវត្ត និង ឬដែលត្រូវចាប់ផ្តើមអនុវត្ត
- ការគ្រប់គ្រងទ្រព្យសម្បត្តិ
- ការគ្រប់គ្រងចំណូល-ចំណាយ
- ចាត់វិធានការចំពោះប្រាក់ជំពាក់
- ការគ្រប់គ្រងអង្គភាព និងមន្ត្រី បុគ្គលិកទាំងអស់ដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ... ។ល ។

• **ប្រភេទកិច្ចការទី២** រួមមាន ដូចជា :
  - ការពិនិត្យគំរូបទបញ្ជាផ្ទៃក្នុង និងផ្តួចផ្តើមរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
  - ការរៀបចំ និងអនុម័តដីកាស្តីពីបទបញ្ជាផ្ទៃក្នុង
  - ការរៀបចំប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសម្រាប់រយៈពេល១២ខែ
  - ការរៀបចំផែនការសកម្មភាពរបស់ក្រុមប្រឹក្សារយៈពេល៣ខែ
  - ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលប្រចាំឆ្នាំ





  - ការរៀបចំបង្កើតគណៈកម្មាធិការនានាស្របតាមច្បាប់កំណត់
  - ការរៀបចំការិយាល័យ និងសម្ភារៈការិយាល័យ
  - ការរៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា
  - ការរៀបចំលេខាធិការដ្ឋានបណ្តោះអាសន្នរបស់ក្រុមប្រឹក្សា
  - ការរៀបចំលិខិតផ្សេងៗ ដូចជា លិខិតអញ្ជើញ . . .
  - ការរៀបចំក្តារព័ត៌មាន
  - ការរៀបចំផ្សព្វផ្សាយព័ត៌មានជាសាធារណៈ
  - ការរៀបចំការិយាល័យ និងសម្ភារៈការិយាល័យ
  - ការទំនាក់ទំនងជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ
  - ... ។ល ។

• ប្រភេទកិច្ចការទី៣ មានជាអាទិ៍ :
  - ការជួសជុលផ្លូវបន្ទាន់ (មិនមានកំណត់ក្នុងកម្មវិធីអភិវឌ្ឍឆ្នាំ ២០០៩)
  - ការចាត់វិធានការចំពោះគ្រោះធម្មជាតិ
  - ការចាត់វិធានការប្រឆាំងជំងឺឆ្លង
  - ការរៀបចំពិធីផ្សេងៗដែលអាចមាន
  - ... ។ល ។

• បន្ទាប់ពីកំណត់កិច្ចការសំខាន់ៗតាមប្រភេទនីមួយៗរួចហើយ ត្រូវស្រង់កិច្ចការ ឬសកម្មភាពទាំងនោះចូលក្នុងកូឡោនទី២ "សកម្មភាព" នៃទម្រង់គំរូ "ក" ។

## ☞ ការកំណត់ពេលវេលា

បន្ទាប់ពីកំណត់ និងស្រង់កិច្ចការសំខាន់ៗអស់ហើយ ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវគិតគូរ និងកំណត់ពេលវេលាជាក់លាក់សម្រាប់អនុវត្តកិច្ចការ ឬសកម្មភាពនីមួយៗដែលបានកំណត់នោះ។ ដើម្បីកំណត់ពេលវេលាជាក់លាក់សម្រាប់សកម្មភាព ឱ្យបានជាក់លាក់ ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធអាចពិចារណា និងអនុវត្តលើចំណុចមួយចំនួនដូចខាងក្រោម :

- ចាត់អាទិភាពនៃសកម្មភាព
  - តើសកម្មភាពណាដែលចាំបាច់ និងបន្ទាន់ជាងគេ?
  - តើសកម្មភាពណាដែលចាំបាច់ត្រូវអនុវត្តជាបន្តបន្ទាប់ពីសកម្មភាពដែលចាំបាច់ជាងគេខាងលើ?
  - ការចាត់អាទិភាពនេះ ត្រូវធ្វើជាបន្តបន្ទាប់រហូតដល់អស់សកម្មភាព
- ផ្អែកលើការចាត់អាទិភាពសកម្មភាពខាងលើនេះ ត្រូវកំណត់ពេលវេលាជាក់លាក់សម្រាប់អនុវត្តសកម្មភាពណាដែលចាំបាច់ និងបន្ទាន់ជាងគេមុនសិន។ បន្ទាប់មកទៀត ទើបកំណត់ពេលវេលាសម្រាប់សកម្មភាពដែលមានអាទិភាពជាបន្តបន្ទាប់។
- ការកំណត់ពេលវេលាអាចចាប់ផ្តើមចេញពីគិតថា :
  - តើសកម្មភាពនេះត្រូវអនុវត្តក្នុងខែណា?





  - នៅពេលសម្រេចជ្រើសរើសយកខែណាមួយហើយ ត្រូវគិតបន្តទៀតថា តើគួរត្រូវអនុវត្តក្នុងសប្តាហ៍ទីប៉ុន្មាននៃខែ ដែលបានកំណត់?
  - ឬបើអាចធ្វើបាន គួរត្រូវកំណត់ឱ្យបានជាក់លាក់បន្ថែមទៀតទាក់ទងនឹងកាលបរិច្ឆេទ តើសកម្មភាពនីមួយៗត្រូវអនុវត្តក្នុងថ្ងៃណានៃសប្តាហ៍ដែលបានកំណត់។
  - ...។ល។
- បន្ទាប់ពីកំណត់ពេលវេលាសម្រាប់អនុវត្តកិច្ចការ ឬសកម្មភាពរួចហើយ ត្រូវស្រង់ពេលវេលាទាំងនោះ បញ្ចូលក្នុងកូឡោនទី៣ "ពេលវេលា" នៃទម្រង់គំរូ "ក" ឱ្យបានសមស្របតាមសកម្មភាពនីមួយៗ។

## ☞ ការកំណត់លទ្ធផលរំពឹងទុក

- បន្ទាប់ពីកំណត់ពេលវលាជាក់លាក់ហើយ ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធត្រូវកំណត់អំពីលទ្ធផលរំពឹងទុក ដែលសង្ឃឹមថានឹងទទួលបានពីការអនុវត្តសកម្មភាពនីមួយៗ។ លទ្ធផលរំពឹងទុកដែលល្អ គឺជាលទ្ធផលដែលជាក់លាក់ និងអាចវាស់វែង ឬប៉ាន់ប្រមាណបាន។ ឧទាហរណ៍ : លទ្ធផលរំពឹងទុកពីសកម្មភាព "ការរៀបចំ និអនុម័តបទបញ្ជាផ្ទៃក្នុង" គឺ "បទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ"។

- បន្ទាប់ពីកំណត់លទ្ធផលរំពឹងទុកដែលនឹងទទួលបានពីការអនុវត្តសកម្មភាពនីមួយៗរួចហើយ ត្រូវស្រង់លទ្ធផលរំពឹងទុកទាំងនោះបញ្ចូលក្នុងកូឡោនទី៤ "លទ្ធផលរំពឹងទុក" នៃទម្រង់គំរូ "ក" ។

☞ **ការកំណត់អ្នកទទួលខុសត្រូវ**

- ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធ ត្រូវពិគ្រោះ និងកំណត់អំពីអ្នកទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពដែលបានកំណត់ ។ អ្នកទទួលខុសត្រូវអាចជាបុគ្គលម្នាក់ៗ ឬជាអង្គភាពមួយ ឬជាគណៈកម្មាធិការ ឬក្រុមការងារមួយ ។
- បន្ទាប់ពីកំណត់អ្នកទទួលខុសត្រូវសម្រាប់អនុវត្តសកម្មភាពនីមួយៗរួចហើយ ត្រូវស្រង់អ្នកទទួលខុសត្រូវទាំងនោះ បញ្ចូលក្នុងកូឡោនទី៥ "អ្នកទទួលខុសត្រូវ" នៃទម្រង់គំរូ "ក" ។





ទម្រង់គំរូ "ក"

**ផែនការសកម្មភាពការងាររយៈពេលបីខែ (ខែ.......ដល់ខែ.......ឆ្នាំ២០០៩)**

**រដ្ឋបាល..............................**

| វិស័យ/ផ្នែក | សកម្មភាព | ពេលវេលា (ខែ) | | | លទ្ធផលរំពឹងទុក | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ប្រភេទ : | | | | | | |
| ១. | ១.១. | | | | | |
| | ១.២. | | | | | |
| | ១.... | | | | | |
| ២. | ២.១. | | | | | |
| | ២.២. | | | | | |
| | ២..... | | | | | |
| ប្រភេទ : | | | | | | |
| ៣. | ៣.១. | | | | | |
| | ៣.២. | | | | | |
| | ៣..... | | | | | |
| ៤. | ៤.១. | | | | | |
| | ៤.២. | | | | | |
| | ៤..... | | | | | |

ផែនការសកម្មភាពការងារនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី....

របស់ក្រុមប្រឹក្សា កាលពីថ្ងៃទី.........ខែ.........ឆ្នាំ២០០៩។

.................. ថ្ងៃទី......ខែ..............ឆ្នាំ២០០៩

**អភិបាល**

## ២.៣.២. ការពិនិត្យ និងអនុម័ត

បន្ទាប់ពីរៀបចំសេចក្តីព្រាងផែនការសកម្មភាពនេះ គណៈអភិបាលត្រូវរៀបចំកិច្ចប្រជុំ "គណៈអភិបាល" ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងនោះ។ បន្ទាប់ពីគណៈអភិបាលបានពិនិត្យ និងឯកភាពសេចក្តីព្រាងនោះ អភិបាល ក្នុងនាមគណៈអភិបាលរបស់ខ្លួន ត្រូវធ្វើលិខិតស្នើទៅក្រុមប្រឹក្សា ដើម្បីដាក់បញ្ចូលរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សារបស់ខ្លួន។ លិខិតនោះត្រូវភ្ជាប់ជាមួយអំពីកំណត់ហេតុប្រជុំគណៈអភិបាល ឬរបាយការណ៍ពីការរៀបចំសេចក្តីព្រាងផែនការសកម្មភាពនោះ និងសេចក្តីព្រាងផែនការសកម្មភាព។ រាល់ឯកសារនានាទាំងនេះ ត្រូវភ្ជាប់ជាមួយលិខិតអញ្ជើញប្រជុំ ដែលត្រូវចែកជូនជាមុនដល់សមាជិកក្រុមប្រឹក្សា។ ក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សាត្រូវពិនិត្យផែនការសកម្មភាព ដែលបានដាក់ជូន និងអនុម័តផែនការសកម្មភាពនោះ ប្រសិនបើក្រុមប្រឹក្សាយល់ឃើញថា ផែនការសកម្មភាពរយៈពេលបីខែនេះមានលក្ខណៈត្រឹមត្រូវ។ ប៉ុន្តែប្រសិនបើក្រុមប្រឹក្សាយល់ឃើញថា ការរៀបចំផែនការសកម្មភាពនេះមិនទាន់មានលក្ខណៈត្រឹមត្រូវគ្រប់ជ្រុងជ្រោយ ឬខ្វះចន្លោះសកម្មភាពសំខាន់ៗមួយចំនួន ក្រុមប្រឹក្សាត្រូវធ្វើការសួរបញ្ជាក់ទៅគណៈអភិបាល ឬអាចស្នើឱ្យគណៈអភិបាលធ្វើការកែតម្រូវឡើងវិញ ហើយក្រុមប្រឹក្សាត្រូវពិភាក្សា អនុម័តខ្លឹមសារដែលបានកែសម្រួលនេះក្នុងកិច្ចប្រជុំនោះតែម្តង។ នីតិវិធីនៃការអនុម័តផែនការនេះ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា។





## ២.៣.៣. ការផ្សព្វផ្សាយ

បន្ទាប់ពីអនុម័ត ក្រុមប្រឹក្សាត្រូវចាត់វិធានការផ្សព្វផ្សាយព័ត៌មានអំពីផែនការសកម្មភាពរបស់ខ្លួន។ គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវរៀបចំផ្សព្វផ្សាយអំពីផែនការសកម្មភាពនេះឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មធ្យោបាយដែលអាចផ្សព្វផ្សាយព័ត៌មានទាំងនេះ មានដូចជា :

- បិទផ្សាយលើក្តារព័ត៌មាននៅសាលារាជធានី ឬសាលាខេត្ត ឬសាលាក្រុង ឬសាលាស្រុក ឬសាលាខណ្ឌ ឬ
- បិទផ្សាយនៅតាមកន្លែងសមស្របផ្សេងៗទៀត ក្នុងដែនសម-ត្ថកិច្ចរបស់ក្រុមប្រឹក្សា ឬ
- ផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀត។

## ២.៤. ការអនុវត្តផែនការសកម្មភាពការងារ

គណៈអភិបាល និងអ្នកទទួលខុសត្រូវក្នុងការអនុវត្ត និងអ្នកពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា តាមផែនការដែលបានកំណត់។

ដើម្បីអនុវត្តផែនការនេះឱ្យទទួលបានជោគជ័យ អ្នកទទួលខុសត្រូវអនុវត្ត ត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- ត្រូវអនុវត្តតាមពេលវេលាដែលបានកំណត់ ដោយត្រូវរៀបចំផែនការសកម្មភាពប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែរបស់ខ្លួន

- ប្រសិនបើមានករណីមិនច្បាស់លាស់ អ្នកអនុវត្តត្រូវទំនាក់ទំនងសុំយោបល់ដឹកនាំតាមឋានានុក្រមរហូតដល់គណៈអភិបាល
- អ្នកអនុវត្តត្រូវតែមានការទទួលខុសត្រូវ និងគណនេយ្យភាពនូវអ្វីដែលខ្លួនបានអនុវត្ត
- អនុវត្តសកម្មភាពនីមួយៗរបស់ក្រុមប្រឹក្សា។

## ២.៥. ការតាមដានត្រួតពិនិត្យ និងរបាយការណ៍

គណៈអភិបាល ដោយមានជំនួយពីអ្នកពាក់ព័ន្ធ ត្រូវធ្វើការតាមដានលើការអនុវត្តផែនការសកម្មភាពរយៈពេលបីខែរបស់ក្រុមប្រឹក្សា ហើយត្រូវធ្វើរបាយការណ៍រីកចម្រើននៃការអនុវត្តផែនការសកម្មភាពជូនក្រុមប្រឹក្សានៅរៀងរាល់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារបស់ខ្លួន។ របាយការណ៍ស្ដីពីការរីកចម្រើននេះ ត្រូវស្រង់ចូលទៅក្នុងទម្រង់គំរូ "ខ" ដូចខាងក្រោម។





ទម្រង់គំរូ "ខ"

**របាយការណ៍រីកចម្រើននៃការអនុវត្តផែនការសកម្មភាពការងាររយៈពេលបីខែ (ខែ.......ដល់ខែ.......ឆ្នាំ២០០៩)**

**រដ្ឋបាល.................................**

| សកម្មភាព | ពេលវេលា (ខែ) | | | លទ្ធផលរំពឹងទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|---|
| ប្រភេទ : | | | | | |
| ១.១. | | | | | |
| ១.២. | | | | | |
| ១... | | | | | |
| ២.១. | | | | | |
| ២.២. | | | | | |
| ២.... | | | | | |
| ប្រភេទ : | | | | | |
| ៣.១. | | | | | |
| ៣.២. | | | | | |
| ៣.... | | | | | |
| ៤.១. | | | | | |
| ៤.២. | | | | | |
| ៤.... | | | | | |

................ ថ្ងៃទី........... ខែ............ ឆ្នាំ២០០៩

អ្នកធ្វើរបាយការណ៍